# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ បោះពុម្ពផ្សាយ
អំពីពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកអក្សរសាស្ត្រ: ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម, បណ្ឌិត នៅ
ពុទ្ធសាសនបណ្ឌិត្យ

បណ្ណាធិការ ផ្នែកដំណឹងសាសនា: ព្រះគ្រូបញ្ញាលិក្ខិត កៅ-ស៊ុម អ្នកគ្រូគ្រា
សិស្សនៅសាលាបាលីជាន់ខ្ពស់

## បញ្ជីរឿង

*ផ្នែកអក្សរសាស្ត្រ* — ទំព័រ

ព្រះគ្រូសង្ឃវិជ្ជ ពាង-សុខ . . . លក្ខណៈ ពាក្យកាព្យ . . . . . . . . ២២៥
លោក ហាន់-យេង . . . . . . រឿងកំពូលកំសត់ (តមក) . . . . . . . ២២៩
ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . . រឿងអង្គរ ក្នុងសតវត្សទី ១៣ តាមសេចក្ដីកត់ត្រារបស់អ្នកដំណើរជាតិចិនម្នាក់ (តមក និងចប់) . . . . . . . . . . . . ២៤២
. . . . . . . . . . . . . . រឿងព្រេងខ្មែរ: រឿងចៅកាំបិតបន្ទោះ (តមក) ២៦១

*ផ្នែកសាសនា*

ហ្លួងនិពន្ធមន្ត្រី ញ៉ុក-ថែម . . . ឯកភាព នៃមិលិន្ទបញ្ហា (តមក) . . . . . ២៧១
ឃុនបណ្ណាគារក្ស ប៊ូ-ប៉ូ . . . . ពិធីបុណ្យក្នុងពុទ្ធសាសនបណ្ឌិត្យ . . . . . ២៧៦
ដំណឹងពីក្រសួងធម្មការ . . . អំពីតាំងជាអធិការនិងមន្ត្រីសង្ឃ . . . . . ២៨៣

ឆ្នាំទី ១៦ — លេខ ៥ ខែមេ ឆ្នាំ ១៩៤៤ — តំលៃប្រចាំ: ១ ឆ្នាំ ១៥ រៀល ។

No 5, Mai 1944
M. 8° 1451

# KĂMPŬCHĔASŎRĬYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

Rédacteur en chef de la partie littéraire: Luong Nibandhamantri Nhok-Thêm, Pandit à l'Institut Bouddhique.

Rédacteur en chef de la partie religieuse: Preah kru Paññalikhito Kao-Sim, Surveillant général de l'École Supérieure de Pāli.

## TABLE DES MATIÈRES

**Partie littéraire:**

| | | Pages |
|---|---|---|
| Prĕah kru Saddavīdū Peang-Sok . . . . . . | Cānakyaçataka, poème. . . . . . . | 225 |
| Monsieur Han-Yéng . . . . | Kămpul kămsăt, roman (suite) . . | 229 |
| Luong nīponmontrei Nhok-Thêm. . . . . . | Angkor au 13e siècle d'après un voyageur chinois (suite et fin). . | 242 |
| . . . . . . . . . . . . . | Conte populaire cambodgien inédit: "Rŭơng chau kămbĕt băntŏh". (suite). . . . . . . . . . . . | 261 |

**Partie religieuse:**

| | | |
|---|---|---|
| Luong nīponmontrei Nhok-Thêm. . . . . . | Ekabhāga-Milindappañhā (suite). | 271 |
| K'ūa pănnanurak Bou-Po | Cérémonies à l'Institut Bouddhique | 276 |
| Communiqué du département des Cultes. . . . | Nominations de Chau at'ikar et Montrei săng . . . . . . . . | 283 |

16e année — N° 5. Mai 1941 — Abonnement: un an 15$00.

# ចាណក្យគតកៈ

## ប្រជុមគតកៈ

### ព្រះគ្រូសង្ឃវិជ្ជ ពាង-សុខ

ក្រុមជំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

ប្រែនិងរៀបរៀង

## ចាណក្យគតកម្មិ

(១) នានាសាស្ត្រុទ្ធតំ វាក្យំ កដទិតសមុច្ចយមិ ។
សវំតីជមិទំ គាស្ត្រមិ ចាណក្យំ សារសំគ្រហមិ ៕

## ចាណក្យគតកៈ

(១) ខ្ញុំនឹងថែងសាស្ត្រ ដែលឈ្មោះថាចាណក្យៈ
នេះដែលជាពីជៈ នៃសាស្ត្រៈទាំងពួងពិត ។
ដែលជាទីប្រជុំ ជាទីផ្តុំនៃភជនីតិ
ជាទីរូបចួបជិត សេចក្តីពិតដ៏ជាសារ ។
គឺខ្ញុំឯងបានជ្រើស គឺបានរើសតែត្រង់ការណ៍
នៃពាក្យដ៏ជាសារ ដែលអាចារ្យបានតែងទុក ។
ក្នុងតម្រានានា បរកមកជាក្បួនត្រឹមៗ
គឺយកមកតែងទុក ជាទំនុកក្នុងក្បួនខ្ញុំ ។

( ២ ) មូលសូត្រំ បវក្ស្យាមិ ចាណក្យេន យថោទិតម៑ ។
យស្យ វិជ្ញានមាត្រេណ មូឍោ ភវតិ បណ្ឌិតៈ ៕

( ២ ) ជនក្មេងទៅជាប្រាជ្ញ ដោយត្រឹមអាចមានប្រាជ្ញា
ចេះមូលសូត្រឯណា ក៏បានថាជាបណ្ឌិត ។
ខ្ញុំនឹងពោលមូលសូត្រ តោះសម្រិតតាមជានពិត
របស់ព្រាហ្មណ៍បណ្ឌិត មានឈ្មោះពិត ចាណក្យៈ ។

( ៣ ) វិទ្វត្តញ្ច ន្ឫបត្តញ្ច នៃវ តុល្យំ កទាចន ។
ស្វទេសេ បូជ្យតេ រាជា វិទ្វាន៑ សវ៌ត្រ បូជ្យតេ ៕

( ៣ ) ដំណើរជាអ្នកប្រាជ្ញ ដំណើរអាចរបស់ស្តេច
មិនស្មើដោយដាច់ស្រេច ព្រោះថាស្តេចគេបូជា ។
ក្នុងប្រទេសខ្លួនពិត ឯបណ្ឌិតជនរាល់គ្នា
តែងតាំងគ្នាបូជា ក្នុងសព្វគ្រប់ប្រទេស ។

( ៤ ) បណ្ឌិតេ ច គុណាៈ សវ៌េ មូខ៌េ ទោសា ហិ កេវលម៑ ។
តស្មាត៑ មូខ៌សហស្រេភ្យ ប្រាជ្ញ ឯកោ វិឝិឞ្យតេ ៕

( ៤ ) គុណទាំងឡាយទាំងអស់ ជារបស់មានក្នុងប្រាជ្ញ
ឯទោសខ្លួនកំណាក ទាំងអស់អាចមានក្នុងខ្លៅ ។
ហេតុនោះខ្លៅមួយពាន់ ក៏មិនទាន់ពិល់ដំរក់
ដែលអាចប្រៀបធៀបទៅ នឹងដំរៅនៃប្រាជ្ញម្នាក់ ។

( ៥ ) មាតុវត៑ បរទារេសុ បរទ្រព្យេសុ លោឞ្ឋវត៑ ។
អាត្មវត៑ សវ៌ភូតេសុ យៈ បឝ្យតិ ស បណ្ឌិតៈ ៕

(៥) ជនឃើញប្រពន្ធគេ　　ជាដូចមេគំមាតា
ឃើញទ្រព្យជាដូចដា　　ដុំពសុធាដោយជាក់ស្តែង ។
ឃើញសព្វសត្វទាំងឡាយ　　ជាដូចកាយនៃខ្លួនឯង
ជននោះត្រូវប្រាជ្ញថែង　　ដោយជាក់ស្តែងជាបណ្ឌិត ។

(៦) *កឹ កុលេន វិសាលេន　　គុណហីនស្ស យោ នរៈ ।*
*អកុលីនោបិ សាស្ត្រជ្ញោ　　ទេវតាបិ បូជ្យតេ ॥*

(៦) ជនដែលប្រាសចាកគុណ　　ចាត់ជាស៊ុនជាអប្បយស
ទោះមានត្រកូលខ្ពស់　　នឹងមានយសក៏មិនល្អ ។
ជនដែលចេះសាស្ត្រ　　ទោះកើតជាត្រកូលក្រ
គាប់ក៏ចាត់ថាល្អ　　ទេវតាក៏បូជាផង ។

(៧) *រូបយោវនសំបន្នា　　វិសាលកុលសំភវាៈ ।*
*វិជ្ជាហីនា ន សោភន្តេ　　និគ្គន្ធា ឥវកឹសុកាៈ ॥*

(៧) ជនមានរូបល្អ　　កើតក្នុងត្រកូលវិសាល
តែវិជ្ជាគ្រាកាល　　មិនត្រែអាលរៀនមុឹងម៉ាត់ ។
ជននោះទោះមានយស　　ក៏មិនខ្ពស់ដោយសម្បត្តិ
ដូចផ្កាចារខ្ចាយខ្ចាត់　　ក្លិនបង់បាត់ឥតភាយសោះ ។

(៨) *តាកណំ ក្ខុបណំ បវេទ្រា　　នារីណំ ក្ខុបណំ បតិ ।*
*បុប្ផវិជ្ជា ក្ខុបណំ ភជា　　វិជ្ជា សវិស្ស ក្ខុបណំ ॥*

(៨) ព្រះចន្ទ្រជាគ្រឿងស្អាង ផ្កាយជិតខាងនឹងផ្កាយឆ្ងាយ
ប្ដីជាគ្រឿងស្អាងកាយ ស្ត្រីទាំងឡាយជាតិលោកិយ ។
ស្ដេចកបដោយសំណាង ជាគ្រឿងស្អាងនៃផែនដី
វិជ្ជាល្អប្រិមប្រិយ ស្អាងប្រុសស្រីទាំងអស់គ្នា ។

(៩) មាតា សត្រូ បិតា វេរី យេន ពាលោ ន បាឋិតោ I
ន សោភតេ សភាមជ្ឈេ ហំសមជ្ឈេ ពកោ យថា II

(៩) កូនតូចដែលជនណា ជាមាតាឬបិតា
មិនឲ្យរៀនវិជ្ជា រីមាតានោះជាខ្មាំង ។
បិតានោះឈ្មោះថា មានវេរលាក់ចិត្តទាំង
កូននោះមិនអាចតាំង ខ្លួនឲ្យតាំងដោយវិជ្ជា ។
ជាអ្នកមិនវិសាល នាកណ្ដាលនៃសភា
ប្រៀបឲ្យឃើញដូចជា កុកនៅនាហ្វូងពួកហង្ស ។

(១០) វរមេកោ គុណី បុត្តោ ន ច មូខ៌ឝតៃរបិ I
ឯកឝ្ចន្ទ្រស្តមោ ហន្តិ ន ច តារាគណៃរបិ II

(១០) កូនមានគុណទ្រសួយ នោះតែមួយគង់ប្រពៃ
កូនល្ងង់នោះច្រើនក្រៃ មិនប្រពៃមិនចំណាន ។
ព្រះចន្ទ្រតែមួយពិត ច្រានងងឹតឲ្យខ្ចាត់បាន
ផ្កាយច្រើនកោសប្រមាណ មិនអាចច្រានងងឹតឡើយ ។

## រឿងកំពូលកំសត់

### លោកហាង-យេង តែងនិងរៀបរៀង

(តមក)

សុភិទ្រស្ទើរតែពាក់ខោអាវមិនទាន់ ក៏ដើរទាំងក្រខាកណ្ដាបក្បាត់សេចក្ដីងងឹតទៅ ឮសូរគ្រលរពោលសំឡេងស្អកៗ មកក៏ព្រួចព្រឺតួសញាក់ក្ដីកាយញ័រចំប្រប់ទៅដោយសេចក្ដីខ្លាច បែកញើសប៉ុនគ្រាប់ពោតលើ-ថ្ងាស លុះដល់ប្រកតូបមានដើមឈើដុះដង្គុត សេចក្ដីអង់អាចរបស់កុមារក៏ទ្រុតទ្រោយចុះ ស្រាប់តែបន្តិចក៏ដល់ទីប៉ាទាវគ្គ កន្លែងដែលល្បីថាលង់ជាទីបំផុត ក៏ញ័ររន្ធត់សក់ឡើងសំពោងឡើងស្បែកគគ្រុកមួយរំពេចក៏រញ្ញកចង់ថយមកក្រោយ រត់ត្រឡប់មកផ្ទះវិញយ៉ាងប្រញាប់ តែលុះនឹកដល់ម្ដាយចុងកំពុងកេងផ្ទះឯណោះ នឹកដល់ព្រនង់ដែលចាំវាយខ្នងក៏ឈប់ភ្ញាមត្រោះទៅកន្លែងដដែលវិញ គោងតែកាត់កន្លែងបូជាសពច្មើដូចម្ដេចហ្ន៎? ក៏កាត់ចិត្តធ្មេចភ្នែកទាំងពីរដើរយ៉ាងលឿនទឹកក្នុងពោះថា

“តាមតែសោគណាចុះ”!

កំពុងតែក្រវល់ក្រវាយក្នុងចិត្ត ស្រាប់តែមានសំឡេងឆ្មា ខ្យាវៗលាន់ឮឡើង ហាក់ដូចជាដំណើរខ្មោចបិសាច សុភិទ្រញ័រជើងវិលមុខស្ទាបបានដំបងមួយហើយធ្មេចភ្នែករត់តែម្ដង ផុតវគ្គបានហានបើកភ្នែក

-

ដើរបន្តិចទៅឃើញមានសត្វអ្វីព្រលៗស្អុំៗអីហ្នឹង! ម្ដេចល្ងង់ទេដឹង!

មេធ្មាសោះ រកតែភ្លុនប្រឡែងគ្នាលេង សុគន្ធក៏ឈូរទ្រឹងបន្តិច ហើយ

ចូនជាផ្ទះនោះគឺផ្ទះយាយម៉បនោះឯង ។

លុះយាយម៉បមកដល់ហើយ ក៏ប៉ុនជួយផ្សែផ្សែរសៃសនាយគាយ

សុវណ្ណបុប្ផាក៏សម្រាលកូនឆាយប់នោះឯង សុគន្ធត្រូវធ្វើបន្ទប់អាំងភ្លើង

រៀបដើងគ្រានជុតឲ្យផ្សែងហើយនៅថែទាំភ្លើងឲ្យក្ដៅស្មើ ដេកហាំនៅប៉ុន

ត្រៃក្រែងម្ដាយប៉ុនត្រូវការប្រើហុចនេះហុចនោះ អង្គុយបណ្ដើរ ដេក

បណ្ដើរត្រូវគ្មានបណ្ដើរ អត់ងងុយយប់នោះឯងទាល់ភ្លឺ សំណាងបាន

ថ្ងៃនោះ ជាពេលឈប់ម៉ែនត្រូវមៅរៀនអក្សរផង ។

ដល់អាំងភ្លើងបាន ៣ ថ្ងៃទម្លាក់ជើងគ្រានស្រួលបួល សុគន្ធក៏ត្រូវ

បំពេញនាទីជាមេឌំ បបំពោរទារកដែលទើបនឹងកើត ព្រោះគេជួលគេ

ពុំបាន ដោយសុវណ្ណបុប្ផាកាចក្រញេងក្រញាងហួសខ្នាត ។ សុគន្ធគេ

ពេលស្មាធ្យាយបានដោយលំបាក ក៏ក្ដុះថ្នាក់បាញ់គេពីរបីនាក់ ត្រូវគេ

ឌឺដងឲ្យថា : " អញស្មានជាក្នុងព្រះសុមេរុគ្មាននរណាឡើងដល់ទេ ឥឡូវ

ឯណាអញក៏ខ្ទង់ផុតទៅទៀត អស់អួតហើយពួកគេនយើង" ។

"គួរឲ្យអាណិតគ្នាណាស់ហ្ន៎! ប្រុសអីធ្វើស្រីស៊ីឈ្នួលមើលកូនខ្ចី

គេទៀត" ក្នុងសិស្សផងគ្នានិយាយចំអកឲ្យសុគន្ធ ។

សុភទ្រអត់ទ្រាំមិនបានក៏ឆ្លើយថា "កុំនិយាយច្រើនពេកអាពួកម៉ាក បែកទ្រូងអញស្លាប់ឥឡូវហើយ" ។

"អ៊ើយស្លាប់ទៅដូចរយទេ ល្ហើយកុំភ័យចាំអញផុត" ។

សុភទ្រក៏ស្រក់ទឹកភ្នែករំពឹងគិតថា " ខ្លួនអញនេះ កើតមកក្នុងត្រកូលគួរសមនឹងគេដែរ ចុះហេតុអ្វីក៏មកវេទនាដូច្នេះ គឺមកតែអំពីម៉ែសុវណ្ណបុប្ផាទាំងអស់ បានជាអញធ្លាក់ខ្លួនលំបាកគោកយ៉ាកព្រាត់ប្រាសម្តាយ ពួកកៀនទាំងឡាយក៏មើលងាយគ្រប់គ្នា ល្ហើយអញទ្រាំឲ្យផុតបីខែទៀតចុះ បើប្រសិនជាសំណាងមានប្រឡងជាប់ នឹងទៅសូមការធ្វើឯក្រុងភ្នំពេញឯណោះ នឹងបានស៊ើបដំណឹងសួរគេអ្នកម្តង ទុកស្តាយណាស់ ឯងក្មេងគិតស្មើលំនៅលោកតាទៅ គ្រាន់នឹងផ្ញើសំបុត្រសួរដំណឹងជំនួប ។ ចំណែកអ្នកក៏ពុំភ្លេចកូនដែរ បានផ្ញើសំបុត្រមកសួររាល់ៗខែ តែសំបុត្រនោះត្រូវអាចារ្យអូសទុកយកទៅឲ្យប៉ា ហើយប៉ាលាក់សំបុត្រនោះ ព្រោះម៉ែសុវណ្ណបុប្ផាមិនអនុញ្ញាតឲ្យៗ មក "ឱអាត្មាអញអើយ! វេទកម្មអ្វីក៏យូរម្ល៉េះដូច្នេះ ។

## បទទី ៨

# សុភទ្រសម្លាប់ខ្លួនឯង

មានថ្ងៃល្ងាចមួយនោះ សុភទ្រកុមារអង្គុយលេងនៅរានហាលខាងក្រៅ ពោលទន្ទឹងភ្នែកគន់មើលជើងមេឃ ពេលនោះស្វាក់ចៀប

ពុំគួរស្រើអ៊ែក្រៅអំពីស្លឹកឈើជ្រុះទៅលើផែនដី ។ ព្រះអាទិត្យអស្តង្គតយូរណាស់ទៅហើយ តែនៅបញ្ចេញពន្លឺផ្ទុកៗ នៅឡើយ ។ ទស្សន-ភាពបែបនោះ គួរពិតពិលរមិលមើលពន់ពេក មិនចង់ឲ្យដាក់នេត្រាចុះសោះ សុទ្ធតែជាពន្លឺភ្លឺព្រោងព្រាតតាំងអស់ សែនស៊ីផ្អមលុបបាត់ទៅ នៅមានពពកខៀវស្រងាត់ មានឆ្នូតស្វាយព័ទ្ធព័ន្ធជុំវិញនាំឲ្យស្រស់ឡើង ចុះថ្ងៃណោះមេឃក៏ក្រយប់ម៉្លេះ ។

សត្វក្អែកដែលយើងឃើញជាងគេ ទំទទះស្លាបហើរផ្លូងទៅរកទីទំកាត់សំដៅទៅទិសដែលសញ្ញាជាតិរបស់វាស្រែកៗៗ ហៅមក អត្តភាពសោកសៅនេះ មកបំបាំងផ្ទាំងល្អពណ៌ណាប់នាំឲ្យអព្ទុះគួរស្តុក ទទះស្លាបលាក់បទៅគួរឲ្យខ្លាច ទឹកឡើងកាលណាព្រឹទ្ធកាលណោះ សុភ័ក្ត្រគេចចេញយកដៃខ្ទប់មុខមួយសន្ទុះ លុះងើបឡើងពន្លឺចុងក្រោយបំផុតរបស់ព្រះអាទិត្យក៏រលត់សូន្យបាត់ទៅ ទើបព្រះចន្ទឡើងគង់លើព្រះទីនាំងកជរេ បញ្ចេញពន្លឺក្តីចាំងកណ្តាលតារាកក្នុងសាករមួយពេញញាំងពពួកជាតិឲ្យភ្លឺព្រោងព្រាតគួរជាទីសប្បាយ ។

សុភ័ក្ត្រហាក់ដូចជាមានចិត្តអប់អរម្យទៅដោយសេចក្តីស្នេហាស្ពាលក្រែកក្រកាលដល់ជីវិត គេចទឹកគិតដល់ទុក្ខវេទនា ឃើញព្រះចន្ទ្រត្រចះត្រចង់ ក៏មានសេចក្តីសង្ឃឹមដល់អនាគត ព្រោះយប់នោះជាយប់ចូលឆ្នាំថ្មី ស្ពើតណ្ហាកយជាសញ្ញាល្អ ក៏ជាឆ្នាំដែលចាប់ផ្តើមឡើងនេះ

នឹងនាំមកនូវសន្តិសុខគ្រប់ប្រការ  នគរបុរក៏បានឲ្យសព្ទសាធុការពរដល់សុភទ្រជាអនេកបរិយាយ  ជាហេតុនាំឲ្យកុមារព្រឺព្រួចក្នុងចិត្ត ហើយបន្លឺនូវវាចាតបពាក្យឡើងថា : .

« ឱព្រះចន្ទ្រអើយ !  លោកជាសាក្សីដ៏សក្តិសិទ្ធិនៃជីវិតរបស់ខ្ញុំ លោកតែងគោចរជានិច្ចជុំវិញចក្រវាឡ  តែងបានឃើញទឹកភ្នែកហូរលើភ្នែកខ្ញុំជារឿយៗ តែងលួងលោមខ្ញុំនាពេលទុក្ខម្នោម្នេញ ដោយជប់ដំណក់ទឹកភ្នែកឲ្យក្លាយទៅជាត្បូងពេជ្រ  ក្នុងឆ្នាំដែលផុតទៅហើយនេះ ខ្លួនខ្ញុំប្រទូកប្រទាក់ច្រើនលើកច្រើនគ្រាណាស់  ដូចខ្ញុំបានសារភាពរៀងៗមកហើយ ថ្ងៃណេះលោកផ្លាស់ព្រះទ័យនាំឯករាជថ្មី គួរឲ្យខ្ញុំមានចិត្តត្រេកអរសាទរសរសើរគុណបារមីនៃលោកជាពេក ហេតុនេះ ខ្ញុំមានសង្ឃឹមទុកក្នុងចិត្តយ៉ាងមាំថា  អំណើះតទៅមុខនឹងបានសេចក្តីសុខសប្បាយក្សេមក្សាន្ត ដោយគ្រោះកំណាចក៏នឹងក្លាយទៅជាសិរីសួស្តីជោគជ័យល្អឡើងវិញ  ឯទុក្ខម្នោម្នេញនឹងរសាយរលាយបាត់សន្តាន  តាំងពីក្រនេះជាដើមដរាបរៀងទៅ ; ជីវិតរបស់ខ្ញុំកាលអំពីមុននោះ  ឧបមាប៊ីដូចជានាវាបណ្តែតលោលកណ្តាលទន្លេ រកកោះត្រើយគ្រាន់នឹងពឹងពាក់ពុំមាន យោងយោងទៅមកដោយរលកព្យុះព្យាមា  តែឥឡូវនេះបានស្ងប់ខ្យល់ ហើយមុខជានឹងមានសង្ឃឹមថា  នឹងរកកោះត្រើយចតបានដោយមិនពិបាក ។

បុងចំផុតទឹកភ្នែកក៏ហូរហៀរមកដោយសេចក្ដីត្រេកអរសោទរ រួចទើបក្រោកចាកទីនោះចេញទៅលេងខាងក្រៅ ។

សុភិទ្រដើរទៅជិតទីផ្សារមួយយ៉ាងធំទូលាយ ជាទីដែលពួកកុមារកុមារីបានមកសន្យាគ្នាថា នឹងមកជួបជុំគ្នានៅវេលាដែលមានបុណ្យមានដើម្បីនឹងលេងល្បែងផ្សេងៗ ព្រោះនៅស្រុកនោះ ជាតិខ្មែរនៅកាន់ទំនៀមទម្លាប់របស់បុព្វបុរសនៅឡើយ មិនបានលះបង់ចោលចង់បានឲ្យទាន់សម័យដូចគេ ហើយអ្នកស្រុកនោះ ច្រើនជៀសអ្នកនៅក្នុងក្រុងជាអ្នកមិនចេះស្រឡាញ់ជាតិ មើលចុះពេលបុណ្យចូលឆ្នាំថ្មីនៅក្រុងក៏ពេញឲ្យស្ងាត់សូន្យដូចថ្ងៃធម្មតា មិនទំនងតាមប្រវេណីពីបុរាណសោះ បើខាងល្បែងស៊ីសងវិញនោះ ឃើញជាគេគ្រាន់បើជាងយើងមែន ព្រោះការប្រជុំរបស់គេនោះនៅក្នុងពាក្យប៉ុណ្ណោះ "ចេញលុយពីកាបៅ" ហេតុនេះឯងហើយដែលនាំឲ្យជីវិតសាបសូន្យ នាំឲ្យអនាគតមិនទៀងនាំឲ្យជាតិអប្បខុន បើប្រសិនណាជាខ្មែរទាំងអស់គ្នា បោះបង់ចោលទំនៀមទំលាប់ពីដើម លែងនាំគ្នាចូលវត្តអារាមធ្វើបុណ្យដាក់ទាន លែងនាំគ្នាលេងល្បែងសម្រាប់ស្រុកនោះ ជីវិតក្នុងកម្ពុជរដ្ឋទាំងមូលមិនខុសគ្នាអំពីជីវិតរបស់សត្វសារិកាកែវ ដែលមនុស្សបានចាប់យកមកក្រុងទុកក្នុងទ្រុងនោះទេ ។

លើទីផ្សារនោះ ពួកក្មេងៗ នាំគ្នាលេងអង្គញ់ស្រុះស្រាឡើង ស្រែកទ្រហឹងអឺងកងរំពងពេញភូមិ ខ្លះលេងហ៊ីងសើចក្អាកក្អាយ ខាងចាញ់ត្រូវគេញីងត្រចៀកបណ្តើរហូតដល់ទី គេបង្ខំឲ្យស្រែកថា “ហ៊ីងៗ” បណ្តើរផង បើដាច់ត្រឹមណា ត្រូវបង្កើនទីរត់កាន់តែឆ្ងាយឡើងទៀត ។ ខ្លះលេងលោតអន្ទាក់លាក់កូនកន្សែងបោះឡើងគ្នាគ្រឹកគ្រេង សុកស្ត្រីទឹកចង់ចូលលេងទឹងគេដែរ តែខ្មាសខ្លួនក៏ដើរហួសទៅដល់កន្លែងគេលេងឈូង ពួកកំលោះឈរត្រង់ជួរប្រឈមគ្នាខាងម្ខាង ពួកក្រមុំខាងម្ខាង នាំគ្នាបោះឈូងចុះឡើងតាមសង្កាត់អ្នកប្រឆាំងគ្នានៅបៀតនោះ ដែលបោះបោះទៀត គឺបានរើសមួយគូម្នាក់ជាស្រេច គឺគប់ឲ្យប៉ះតែរូបអ្នកដែលខ្លួនត្រូវការនោះឯង កំលោះជម្រើសកន្សែងនារីណា ដែលមានចិត្តជើតជាប់គេ បើបានខាងបោះគប់គេវិញនោះ មានសេចក្តីត្រេកអរជាពន់ពេក ចាប់ចិត្តតែរូបខាងមួយប៉ុណ្ណោះ ចំណែកពួកក្រមុំវិញទុកជាតាបចិត្តលេងខឹងរូបណាក៏ពុំហានបោះតែអ្នកនោះរឿយៗ ឡើយ គឺបោះបោះខាងណោះម្តងខាងណោះម្តង តែគូប្រុសប្រាណនោះត្រូវបោះច្រើនជាងគេ ។

ចំណែកខាងសុកស្ត្រីកុមារ ក៏ដើរទៅអង្គុយលើគល់ឈើមួយចាំស្តាប់គេប្រៀង ហួសនឹកដល់ឱកាសបួលឆ្នាំមុននោះ ក៏ចាំបានថាមានកុមារីម្នាក់ឈ្មោះខាងសាលី អាយុ ១២ ឆ្នាំដូចគ្នា បានសន្យានឹងមកជួប

លេងជាមួយគ្នាទៀតដល់ឆ្នាំនេះ ឥឡូវដល់ពេលហើយនាងក៏ពុំឃើញមក នាងក្អេបពាក្យសន្យាហើយទេដឹង ទឹកឡើងគួរឲ្យស្រណោះដល់ចម្រៀងឈ្នួងណាស់ហ្ន៎ ទើបក្លាត់មាត់ស្រែកច្រៀងយ៉ាងខ្លាំងៗ ថា៖

"បងពោះឈ្នួងទៅ ឈ្នួងបែកជាពីរ ទឹកដល់ឆ្អូនស្រី......" ។

ស្រាប់តែឃើញរូបនាងសាលីច្បាស់នឹងភ្នែក នាងស្លៀកខ្មៅពាក់ខ្មៅ កងគូបស្តើងមូលខ្ញុំសមនឹងសំលៀកបំពាក់ មុខមាត់ស្រស់ញញឹមដូចបន្ទូរពេញបូណ៌មី ថ្ពាល់ពេញរលោងស្អាតបិបមេម្យ៉ាបំព្រងផង ភ្នែកទាំងគូខ្មៅស្រិលដូចទឹលជេញផ្ទេកៗ សក់រួញកញ្ចាញ់ដូចលេកគ្រវទ្រលប់មកមកក៏ជាត់ជាយទៅក្រោយគួរឲ្យទស្សនា ។ ឃើញដូច្នោះសុកន្ទ្រស្មានជាយល់សប្តិ ដល់នាងសើចមករកទើបក្សាក់ខ្លួនងើបឈរឡើង ។

"សុកន្ទ្រឯងទើបនឹងមកពីណា ខ្ញុំរកមិនឃើញ កុំចិត្តមើលទៅស្មានជាខ្ញុំក្អេបពាក្យសន្យាហើយ" ។

អរគុណហើយសាលី ខ្ញុំមិនត្រូវការលេងផងទេឆ្នាំនេះ ឯងទៅលេងចុះ ទុកឲ្យខ្ញុំអង្គុយស្តាប់បានហើយ ។

"បើឯងមិនទៅលេង ខ្ញុំក៏មិនទៅដែរ បើដូច្នោះយើងទៅអង្គុយលេងមាត់ទឹកប្អូន ចាន់ខែក៏សប្បាយ!

គេទាំង ២ នាក់ព្រមគ្នា ក៏ត្រសង់ទៅកាន់កំពង់ទឹក ទៅត្រង់ណោះឮសូរសព្ទធម៌លាន់សន្ធឹមៗ ចេញពីគ្រប់កុដិ បន្តិចកំពង់ពេងឡើងជាលំដាប់ មួយៗដដែលៗ ពីរោះលន្លោចគួរឲ្យចាប់ចិត្តចង់ស្តាប់ ឮសូរល្វេងល្វើយតាមខ្យល់មក ហាក់ដូចចម្រៀងយ៉ាងគោរម្យបំផុត អាចនឹងសន្ទំកំពូលគមលឲ្យស្ងប់ស្ងាត់ អាចលួងលោមឲ្យត្រជាក់ចិត្ត ទុកជាមានទុក្ខអផ្សុកអផ្សាន្តយ៉ាងណា កាលបានឮសព្ទព្រះធម៌ហើយ គង់នឹងរសាយមួយរំពេច បីតិក៏កើតមានឡើង បណ្តាលឲ្យអណ្តែកអណ្ហូង ។

នាងសាលីតាំងសំដីផ្តើមការសន្ទនាឡើង "ស្រុកទ្រូងឯងលំបាកសព្វថ្ងៃនេះ ខ្ញុំដឹងអស់ហើយ ខ្ញុំអាណិតស្មើនឹងស្រក់ទឹកភ្នែក ចិត្តចង់មករស់នៅជាមួយដូចមុនៗទៀត តែឪពុកមិនព្រមអនុញ្ញាតឲ្យ ព្រោះខ្លាចក្រែងមីងសុវណ្ណគាត់វាយ គិតម្តេចបានកូនទ្រូងឯងបានសប្បាយដូចដើមវិញ ?

ណ្ហើយ ! លីកុំគិតដល់ខ្ញុំធ្វើអី ការដែលលីឯងមានចិត្តអាសូរដល់ខ្ញុំនោះជាព្រះគុណសន្ធឹកណាស់ទៅហើយ លីឯងមើលចុះ ធម្មជាតិតាំងមូល កាលបើគ្មានពន្លឺព្រះចន្ទហើយ ក៏ងងឹតសូន្យគួរឲ្យខ្លាចគក់ស្មុក តែកាលបើព្រះចន្ទត្រឡប់មកវិញ ក៏បំព្រងរីករាយឡើងវិញ ឯជីវិតយើងរាល់គ្នាក៏ដូច្នោះដែរ ហេតុនេះកុំលីព្រួយចិត្តព្រោះខ្ញុំអី មិត្រដែល

ស្គាល់គ្នាកាលគ្រាក្រនេះមានតិចណាស់ ក្នុងស្រុកកំពង់ធំនេះមានតែលីឯងហើយ បើដូច្នោះលីឯងកុំគួបចិត្តអ្វី ខ្ញុំនឹងសុំលីឯងជាប្អូនបង្កើត ហើយលីឯងនឹងឃើញដល់ខ្ញុំជាបងបង្កើតរបស់លីឯង" ។

"ពុះមានអីបង ខ្ញុំក៏សុខចិត្តព្រមដែរ បើបងមានកិច្ចការអ្វីភាណពិត ប្រាប់ប្អូនៗនឹងជួយមិនខាន ព្រោះប្អូនក៏កំព្រាដូចបងដែរ" ។

នៅស្ងៀមមួយស្របក់ សាលីនិយាយឡើងថា "សុកិន្ទ្រមើលទឹកថ្លាហូរចុះសន្សឹមៗ ទៅកេខទ្វេងនាយឯណោះ បើតែស្រកស្រុតទៅជាដកប តែដល់ពេលខែទឹកឡើង គឺនឹងពេញប្រៀបឡើងវិញមិនខាន យ៉ាងណាមិញ ជីវិតរបស់មនុស្សក៏គង់មានដោរនាប់ដូច្នោះដែរ បើដូច្នោះយើងគោរតែស៊ូដល់សេចក្ដីលំបាកកុំឲ្យបង់សេចក្ដីព្យាយាម ថ្ងៃក្រោយទៅ មុខជានឹងបានសមដូចសេចក្ដីប្រាថ្នាមិនខាន" ។

ក្មេងទាំងពីរមិនបាននិយាយអ្វីៗតទៅទៀត នាំគ្នាដើរត្រឡប់មកផ្ទះវិញ មានសេចក្ដីរីករាយតែរៀងខ្លួន សុកិន្ទ្រមានទឹកចិត្តសង្ឃឹមជាប់ជា នឹងគន្ធផុតគំពីគ្រោះកាចជាមិនខាន ព្រោះបានបាងសាលីជួយការពារ ម្យ៉ាងវិញទៀត ចម្ងាគុតុទាំងពួងពោះតូចក្ដីធំក្ដី កាលបើគេសង្កត់ហើយ មុខជាវិតតែតែវុតឡើងវិញ បុះបើបានថ្លែងប្រាប់គេប្រាប់ឯងវិញ ហើយខានគេផ្ដួលឈ្លោល ទុកជាធ្ងន់យ៉ាងណា ក៏គង់នឹងស្រាលវិញជាមិនខាន បំណាកភាន់មនុស្សលោក ច្រើនមាននិស្ស័យ

ចង់ចរចាអំពីសេចក្តីសុខរបស់ខ្លួនជាដរាប ចង់សំដែងទឹកចិត្តរបស់ខ្លួន ទឹងចរិតក្នុងចិត្តឲ្យគេដឹងឮផង ដោយហេតុនេះបានជាមនុស្សផ្តុំគ្នាជាពួកជាក្រុមជាសមាគមឡើង ។

លុះសុភទ្រមកដល់ផ្ទះវិញ ឪពុកបិតារបស់ខ្លួនកំពុងនិយាយជាមួយនឹងភរិយាចុង យប់នោះដឹងដោយហេតុអ្វី បានជាសោភិតស្រួលចិត្តកកូនសួរថា «កូន! កូនឯងមិនទៅលេងទីងគេទេឬ? ព្រញាប់ដេកម្ល៉េះមិនទាន់យប់ជ្រៅប៉ុន្មានទេ" ។

«ម៉ាកប្រសាសន៍លោកប៉ា កូនទើបនឹងមកពីលេងជាមួយនឹងគេ ខ្ញុំមិនហ៊ានទៅយូរ ក្រែងម៉ែឯណេះមិនស្រួល ឬត្រូវការប្រើឲ្យខ្ញុំធ្វើអ្វីៗ" ។

សោភិតអង្អែលក្បាលកូនហើយនិយាយថា «តើនេះបានចំជាកូនប៉ា បេះទឹកដល់ចូនដល់ម្តាយនាងនោះល្អហើយ ឆ្នាំនេះប៉ាចង់គាត់គោការឲ្យកូនពីរបីសំរាប់ ខោអាវមុនៗនោះរហែកអស់ទៅហើយ ម៉ែឯងគេទិញកំណាត់មកហើយ ដល់ស្អែកឯងមើលគាត់ហើយដេរទៅផងចុះ ឯងចេះបេចាស្រាប់ហើយ" ។

សុភទ្រាអ្នកចាំងពីរបួលការខំដំណេក ទឹកព្រួកក្នុងចិត្តជា ប៉ាគាត់ស្រឡាញ់អញថែរទេតើ មុខជាអញបានសុខហើយចាប់ពីថ្ងៃនេះទៅ ក៏ប្រះខ្លួនដេកដោយស្រួល រលងទឹកនាដល់ភ្លឺទៀត យប់

នោះឯងទំព្រាបានសិប់យូរជាងសព្វកាល ត្រាតែចាន់ងើរជាស់តាម ធម្មតា ៗ

ពេលសម្រាករៀន ១ ខែក៏ផុតទៅដោយសេចក្តីសប្បាយ ព្រោះ សោភិតបានអនុញ្ញាតឲ្យពួកកៀនសុភ័ន្រមកលេងជាមួយ បណ្តាអ្នក មកលេងជាមួយនោះ មាននាងសាលីជាដើមនិងពួកក្មេងអ្នកស្រុក នោះៗ ឯនាងសាលីតែងចូលជួយធ្វើការងារជំនួសបងចិញ្ចឹមរបស់នាង ជួយដណ្តាំបាយនិងផ្សំគ្រឿងស្លស្លុក ម្មួយថែទាំប្អូនតូចឲ្យដេម្យទុក ពេលឲ្យបងទៅលេងជាមួយនឹងគេ គឺរត់ប្រណាំងគ្នាលោតខ្សែយក កំពស់ ពុំនោះសោភ បបួលគ្នាទៅបេះផ្កាបងជាកំរងយកមកតាំងផ្ទះ អ្នកជិតខាងឃើញដូច្នោះក៏ទឹកថា មើលទៅសោភិតដឹងខុសត្រូវហើយ ស្គាល់ប្រពន្ធស្គាល់កូនមិនលេងទេ ៗ

លុះដល់ពេលចូលរៀន សុភ័ន្ត្រក៏លាកនលេងត្រប់គ្នា លាទៅ ដោយសេចក្តីស្តាយជាច្រើន ចូលរៀនហើយក៏នៅតែនឹកបង់លេងជា មួយនឹងអ្នកអស់នោះទៀត ចង់ឈប់សម្រាកខ្ទួនតទៅទៀត នឿយ ណាយមិនចង់នៅកន្ទាក់ ព្រោះពេលនោះក្តៅណាស់ហាក់ដូចជាស្មោរ ផ្ទុះច្នះឯង ហើយនៅផ្ទះវិញមានម្លប់ត្រជាក់ល្អ កន្ទាក់ស្ទាត់ឈើងព្ទ តែស្លូរយោហើរធ្លេ្ចា និងស្លូស្លាបបាំកកា ក្រោកៗ លើត្រជាស ស្លូរក្រាំងអស់គ្នាដើតាំឲ្យតែដល់ពេលចេញលេងឆាប់ៗ ពេលចេញ

លេងមកដល់ ក៏នាំគ្នាតែប្រសាចទៅអង្គុយក្រោមម្លប់ដើមស្វាយ នាំគ្នានិយាយពីនេះពីនោះមិនចេះអស់មិនចេះហើយ មិនដឹងជាដើមចុងនៅត្រង់ណា ដែលចំឡែកនោះ គឺគេអនុញ្ញាតឲ្យសុក្រិនចូលសមាគមជាមួយផង លែងគិតរៀលដូចមុនៗទៀតហើយ ព្រោះកុមារស្លៀកពាក់ស្អាតបាតល្អមិនប្រឡាក់ដូចដើមទៀតឡើយ ។

នៅស្ងៀមមិននិយាយស្តី សុក្រិនមិនជាស្តាប់គេនិយាយប៉ុន្មានទេ នឹកទៅរឿងដទៃៗទៅ ដែលអ្នកអស់នោះមិនអាចនឹងដឹងបាន ទោះបើប្រសិនណាជាកុមារអាចនឹងបបួលបែបនេះ នូវអ្នកដែលមានចិត្តមួយថ្លើមមួយនឹងអ្នកនោះ គង់បណ្ដាក្មេងទាំងប៉ុន្មានទៅទីនោះប្រហែលជានឹងសប្បាយណាស់ហើយមើលទៅ ក៏ភ្នកនឹកដល់ប្អូនចិញ្ចឹមរបស់ខ្លួន ហើយក៏ញញឹមតែម្នាក់ឯងនឹកគង់ចិត្តថា អញបាននាងសាលីធ្វើជាប្អូនដូចជាបានពេជ្របានមាស តាំងពីនោះមកក៏បានស្រួលទាំងអស់ អ្នករៀនជាមួយគ្នាក៏លែងធ្វើបាប បាក៏ស្រួលមករក ម៉ែសុវណ្ណសោភក៏ទន់ចិត្តដែរ មិនតឹងតែងដូចមុនពេក ពេលយប់ក៏បានចេះរៀនរៀនស្រួល មិនចាំបាច់ទៅស៊ីឈ្នួលមើលសាស្ត្រាទៀត ។ តាំងពីបែកចាកមាតាទៅនោះ ក៏ទើបស្គាល់ថាអស់មានទុក្ខណា គេរំលង់នឹងខ្លួនហើយ បាននាងសាលីមកជាប្អូនចិញ្ចឹមក៏សង្ឃឹមថាបានសុខ ព្រោះនាងដឹងទុក្ខធុរៈបងណាស់ ចេះលួងលោមឲ្យបាត់ព្រួយ ចេះកំឡាឲ្យសប្បាយចិត្ត ។ (មានត)

# រឿងអង្គរ ក្នុងសតវត្សរ៍ ១៣

## តាមសេចក្ដីកត់ត្រារបស់អ្នកដំណើរជាតិចិនម្នាក់

(តមក)

មនុស្សស្លាប់–. ឯមនុស្សស្លាប់នោះមិនមានក្តារមឈូសទេ គេរុំនឹងកន្ទេល ហើយយកសំពត់រុំកន្ទេលនោះ វេលាហែទៅកាន់ទីបុះធាខាង ប្រើទង់ជ័យ ទង់ក្ដោប មានភ្លេង តាមផ្លូវទៅនោះ គេប្រាយលាជផង ៗ លុះមកដល់ក្រៅក្រុងឆ្ងាយល្មមគ្មានមនុស្សនៅហើយ ទើបគេបោះចោលរូបអស្សុភនោះ ៗ គេចាំមើលត្មាតឆ្កែមកចឹកស៊ីរូបអស្សុភនោះ ៗ ប្រសិនបើមានសត្វមកស៊ីអស្សុភនោះអស់ទៅ គេនិយាយថាញាតិសាច់របស់គេនោះមានគុណសំណាង ហើយពួកគេក៏បានទទួលផលបុណ្យនេះដែរ ៗ ប្រសិនបើសត្វអស់នោះមិនមកស៊ីឬស៊ីតែមួយចំណែក គេថា ឪពុកម្ដាយ ឬញាតិសាច់នោះ មានកំហុសអ្វីមួយមិនខាន ។ ដល់មកឥឡូវនេះ មានមនុស្សនិយមដុតខ្មោចបន្តិចៗខ្លះហើយ ទំនៀមនេះបានមកពីចិន ៗ កាលឪពុកម្ដាយគេស្លាប់ទៅនោះ ពួកកូនៗ មិនបាច់ស្លៀកពាក់កាន់ទុក្ខទេ ប៉ុន្តែកូនប្រុសត្រូវកោរក្បាលចេញ កូនស្រីកោរកាត់សក់ខាងលើថ្ងាស ទំហំប៉ុនកាក់ប៉ុណ្ណោះ នេះជាគ្រឿងសំគាល់សេចក្ដីសោកអាល័យរបស់កូន ។ ឯព្រះមហាក្សត្រិយ៍គេយកទៅកប់ក្នុងប្រាសាទមួយ ប៉ុន្តែមិនដឹងជាគេកប់ទាំងតួព្រះអង្គទាំងមូល ឬកប់តែព្រះអដ្ឋិទេ ៗ

របរក្សេត្រកម្ម– តាមធម្មតាក្នុងប្រទេសនេះ គេធ្វើដំណាំក្នុងមួយឆ្នាំ ៣-៤ លើក ៗ រាល់ៗឆ្នាំ ដូចជាក្នុងខែទី ៥-៦ របស់យើងនោះ ក្នុងប្រទេសនោះ គេមិនដែលស្គាល់ទឹកកកឬហិមៈទេ ៗ មានពាក់កណ្ដាលឆ្នាំជាខែភ្លៀង ពាក់កណ្ដាលឆ្នាំទៀត ជាខែរាំងភ្លៀង ៗ នៅក្នុងខែទី ៤ ដល់ទី ៩ តែងមានភ្លៀងធ្លាក់រាល់ៗ ថ្ងៃក្នុងវេលារសៀល ទឹកទន្លេសាបក៏ជោរជន់ឡើងដល់ ៧ ទឹង ៨ ហាត ដើមឈើធំៗក៏លិចទឹកទៅដល់ផុតចុងក៏មាន ៗ ក្នុងខែទី ២–៣ មិនមានភ្លៀងមួយដំណក់ធ្លាក់មកឡើយ ៗ ទន្លេសាបក៏ស្រកទឹកទៅល្មមទូកខ្នាតតូចចូលទៅដល់ទីដែលមានទឹកជ្រៅបាន ដៀតជម្រៅទឹកត្រឹមបីដល់ប្រាំដើង (១ ដើង ៣៣ សង់ទីម៉ែត្រ) ប៉ុណ្ណោះ ៗ ពួកអ្នកស្រុកក៏នាំគ្នាចុះទៅ អ្នកស្រែក៏គិតគូរពីពេលដែលស្រូវស្រែទុំ ក្នុងឱកាសដែលមានទឹកជោរជន់ឡើងមកលិចទីដីស្រែ ៗ ឯការភ្ជួរស្រែនោះ គេមិនប្រើគោទេ តែនង្គ័លរនាស់កណ្ដៀរមានបែបទំនងដូចរបស់យើងដែរ ឯរបៀបធ្វើខុសផ្សេងពីយើង ៗ កាលណាទឹកឡើងមកបានមួយហាងស្រូវនោះក៏ឡើងតាមទឹកស្មើគ្នា ខ្ញុំគិតថា ជាពូជស្រូវពិសេសមួយយ៉ាង ៗ

ឯការដាក់ជីជីវិនភ្ជួរដីដាំបន្លែនោះ គេមិនបេះប្រើជីអាចម៍សត្វទេ គេខ្ពើមទុកជារបស់មិនស្អាត ៗ ពួកចិនដែលនៅស្រុកនោះ ក៏មិននិយាយប្រាប់ផងទេ តែខ្ញុំស្មានថា គេសំឡឹងមើលដីដែលចិនប្រើជា

របស់ស្លាកគ្រោក ។ កុងពារប៉ុន្តែ គេនាំគ្នាជីករណ្ដៅមួយគេយកស្លឹក ប៉េងប៉ោះ (បន្ទន់ប្រកស្បូវ?) កាលណារណ្ដៅនោះពេញគេកាយលុបដី ហើយទៅជីកកន្លែងផ្សេងទៀត ។ ក្រោយដែលបានបន្ទោរបង់រួច ហើយ គេក៏ទៅងូតទឹកលាងទឹកដោយដៃឆ្វេង ព្រោះដៃស្ដាំត្រូវទុក ចាប់អាហារសម្រាប់បរិភោគ ។ កាលគេបានឃើញពួកបរទេសប្រើក្រ-ដាស (កិតលាមក) គេខ្ពើមខ្ពើមហើយបន្ទោរផ្ទុះតែម្ដង ។

អំពីភាពភូមិប្រទេស - នៅក្រោយផ្ទះស្រុកទេស - ពួ សត្វ ចិញ្ចឹមគស់ ស្ងួតស៊ីងដាំព្រៃព្រឹក្សាលតាល់ដេរដាសពាសពេញនៅ គន់ផ្ទុះរាបរនៀល ជាជ័ន្ទុះធំធំទូលាយមានចំហៀកបរយោល មានមួយ ត្រឈើត្រែកៃលខ្ពស់ ដោយដើមឈើតាសាំ ទីដើមផ្កាវែងៗ ។ ស្រូវ សម្រែកសត្វស្លាបគក់គីរងំ ។ នៅតាក់តណ្ដាលទន្លេ គេមើលឃើញ ដំបូង គឺកំលដំដុះធំធំតាមឈើ ១ ត្នួតទៅ ហើយតទៅទៀត គេឃើញ មានតែតំណជាតំបាំងសំបើម ។ មានក្រប៉ៃព្រៃធំហ្វូងៗ កប់យោកប់ ពេនៅទីនោះ រួចតទៅទៀត មានព្រៃឫស្សីធំទូលាយកប់យោល ឯមែកឫស្សីនោះសុទ្ធតែមានបន្លា ទំពាំងក៏មានរសជាតិល្អណាស់ ។ នៅទីបំពង់ ៤ មានគំនូសៗ ។

អំពីផលានុផល - នៅក្នុងចំការឡាយនោះ មានព្រៃស្រាង ជាច្រើនរបៀប ហើយមានចាំងមោស ដំរីតាស្រែយនៅផង ។ ពួកសត្វ

ស្លាបក្រម ៗ ទាំងសត្វចំឡែក ៗ ក៏មានច្រើនលើសលប់គណនា ៗ ផលានុផលដែលមានដម្លៃច្រើននោះ គឺស្លាបសត្វកដប ភ្លុកដំរី ក្រុយរមាស ក្រមួនឃ្មុំ ដែលមានប្រើច្រើនធម្មតា គឺក្វាង-ចេន, ក្រវាញ, រាំ-រាំង, ឈើ-កេង ប្រេងតា-ហ្វង-ស៊ុ ៗ

សត្វកដបនោះក្រមខឹងចាប់បានណាស់ ៗ ក្នុងព្រៃញឹកនោះតែងមានអណ្ដូង ហើយនៅក្នុងអណ្ដូងនោះមានត្រី ៗ សត្វកដបចេញពីព្រៃទៅរកចាប់ត្រី រាលាក់ខ្លួនពួនទៅក្រោមស្លឹកឈើ ៗ ខ្លះពួននៅមាត់ទឹក គេមានទ្រុងដាក់សត្វកដបញីមួយ ជាផ្លាក់ទាក់តួឈ្មោល ហើយនៅដៃគេកាន់លប់តូចមួយផង ៗ គេអង្គុយចាំសត្វនេះហើរមក ហើយយកលប់នោះរាយទៅ ៗ ក្នុងថ្ងៃខ្លះគេចាប់បានដល់ ៣ ដល់ ៤ ក្នុងមួយថ្ងៃក៏មាន តែចួនកាលចាប់មិនបានឡើយ ហួតអស់មួយថ្ងៃ ៗ

ពួកមនុស្សអ្នកនៅក្ដាំងនោះ គេរើសកែភ្លុកដំរីផង តែមានដំរីមួយស្លាប់ទៅតែងមានភ្លុកពីរជាដរាប ៗ ឯដំរីភ្លុកដែលគេចាក់ខ្ទីងលំពែងស្លាប់នោះជាភ្លុកល្អបំផុត ៗ ភ្លុកបន្ទាប់មក គឺដែលស្លាប់តាយ-សាកតាមធម្មតា ៗ ភ្លុកដែលគេពប់អានតិចទៅទៀត គឺភ្លុកដែលគេរកឃើញនៅក្នុងក្ដុំ ៗ

ក្រមួនឃ្មុំនោះ មាននៅទីងដើមឈើពុកៗ ដែលមេឃ្មុំបានបង្កើតឡើង សត្វនេះដូចជាស្រមោច ៗ ខ្មែរតែងតែទៅយកសំណាក់ឃ្មុំនោះ

ក្នុងទូកនីមួយៗ គេដាក់សំណាកឃ្មុំបានដល់ពីរបីពាន់ សំណាកធំៗ មានទម្ងន់ដល់ ៣០-៤០ លីត្រ សំណាកតូចទម្ងន់ពី ១៨ ដល់ ១៩ លីត្រ ។

កុយមោសសមានសារសៃឈាមគេតែងកប់គានណាស់ លក្ខណៈខាងក្នុងមានសំបុរទៅ ។

ក្រាង-បេនមាននៅក្នុងព្រៃជ្រៅៗ ពួកមនុស្សព្រៃតែងកាប់បំផ្លាញអស់ទៅជាច្រើន ក្រាង-បេននេះជាឈ្មឹមឈើម្យ៉ាង មានសាច់ស្រាយស្រោបជុំវិញប្រមាណ ៨-៩ ពូស (១ ពូស (Pouce O.M. 0255) ដើមតូចៗ មានសាច់ស្រាយតិចជាង ៤៥ ពូស ។

ក្រកញនោះ ពួកមនុស្សព្រៃដាំនៅលើភ្នំ ។

ក៉-ក៉ង ជាជាតិជ័រឈើ ៗ យ៉ាង ៗ ពួកខ្មែរគេវះបោះទុកមួយឆ្នាំមកមុន ឲ្យជ័រហូរចេញឯង ហើយចាំរើសយកក្នុងឆ្នាំជាបន្ទាប់មក ។

ស៊ី-គេង មាននៅក្នុងមែកឈើ ដូចជាសាង-គី បេង ជារបស់គេបានដោយក្រម ។

ប្រេងកា-ហ្វុង-ស៊ុី បានមកពីគ្រាប់ឈើធំមួយយ៉ាង ផ្លែវាដូចផ្លែដូង មានគ្រាប់ផង ។

ម្រេចក៏មានខ្លះដែរ វាដុះនៅជុំវិញដើមឈ្មោះ ហើយចាក់ស្រែះគ្នាដូចស្មៅ ដែលបេះទៅវាមានរសជាតិណាស់ ។

អំពីជំនួញ — នៅក្នុងស្រុកនោះ មានតែពួកស្រីៗទេ ដែលចេះលក់ដូរ ។ មានចិនម្នាក់មកដល់ស្រុកនោះ គេបានធ្វើឲ្យកើតផលចំរើនខាងការលក់ដូរផ្សារច្រើន ។ (នៅស្រុកនោះ) គេមិនមានកន្លែងលក់ដូរជាប់ជានិច្ចទេ. មានតែកំណាត់កន្ទេលក្រាលត្រដាងលើដី ម្នាក់មួយៗ ។ ខ្ញុំបានឮគេនិយាយថា អ្នកលក់ដូរគោរពបង់ពន្ធថ្លៃកន្លែងឲ្យមន្ត្រីពន្ធការ, បើលក់ដូរបន្តិចបន្តួច គេដូរជាស្រូវជាបន្ទុបង្ករ ឬរបស់ចិនលក់ដូរហូតដល់សំពត់ក៏មាន ក្នុងការលក់ដូរធំៗ នោះ ទើបគេប្រើមាសនិងប្រាក់ ។

តាមដែលមើលទៅនោះ ពួកអ្នកស្រុកៗនេះ ច្រើនស្លូតសុភាពណាស់ ។ កាលណាគេបានឃើញចិន គេតែងសំដែងសេចក្តីគោរពខ្លាចគោរពហៅចិនថា ហ្វូ (Fo = Bouddha) ។ តមកមានពេលខ្លះ មានពួកអ្នកខ្លះបោកបញ្ឆោតចិន ធ្វើខុសនឹងពួកចិនក៏មាន ប៉ុន្តែនោះច្រើនតែមនុស្សដែលចំណូលមកថ្មី ។

អំពីជំនួញរបស់ចិនដែលគេត្រូវការនៅស្រុកខ្មែរ-ប្រទេសនេះខ្ញុំជឿថា មិនមានកើតផលមាសប្រាក់ទេ របស់ដែលគេរាប់អានច្រើននោះ គឺមាសនិងប្រាក់ស្រុកចិន បន្ទាប់មកសំពត់សូត្រពណ៌សាច់ស្តើងផ្ទៃពីរ ។ តមកមានផលានុផលអស់នេះ កើតមកពីសំណប៉ា-ហាំងនៅស្រុកចេន-ចៅ, ជាសន្ទុកស្រុកវេន-ចៅ, ចានឃ្លើបពណ៌ខៀវស្រុកឈួន-ចៅ, បារត, ជាតិហិង្គុល, ក្រដាស, ស្ពាន់គរ

ម្សៅ, ទុំមចន្ទន៍, សត្វឈ្លូស, សំពត់សំបកឈើ, សំពត់ស្រុកកាំង-តាវ, តាំងយូ, ឆ្នាំងដែក, ជាសស្លាន់, ការគៅ, ក្រាសឈើ, ម្ជុល, គះទួល, នៅស្រុកមិង-ចៀវ ។ ឯរបស់ដែលគេត្រូវការទិញច្រើន គឺសណ្តែក ទិនស្រូវសាលី តែជារបស់ត្រូវហាមនាំចេញទៅលក់ប្រទេសក្រៅ[១] ។

**អំពីដំណាំ**– ទទឹម, អំពៅ, ផ្កានឹងក្រអៅឈូក តាពេ, បែស, (Pêcher), បេក, ហឺយ៉ុង, (Hiong), មានដូចគ្នានៅស្រុកចិន ។ គួលៃន ខ្មីក្រប មានបែបភាពដូចគ្នាដែរតែដូរ ។ ដើមដំណាំឯទៀតៗ មិនឃើញមានទេនៅស្រុកចិន ។ បំពួកដើមឈើផ្សេងៗ នោះមានច្រើនណាស់ តាំងផ្កាសោតទៀតក៏មានសំបូណ៌ មានក្លិនក្រអូបនិងមានល្អ ។

**អំពីសត្វស្លាប**– បំពួកសត្វស្លាប មានក្អែក, សត្វកង៉ប, សត្វសេកជាសត្វដែលគេមិនដែលស្គាល់ទេនៅស្រុកចិន ។ សត្វស្លាបឯទៀត មានទល្អាត, ក្អែក, កុក, ចាប, ប្រវឹក, តាដក់ ខ្លែងស្រាក, តារ៉ែត, សត្វត្រចៀកកាំបៀង, ឃើញមានសត្វអស់នេះទាំងអស់ ។ ខ្វះតែសត្វល្មាបេក, ក្ងានព្រៃ, Loréol. Tou Yn, សត្វត្រចៀកកាំ ព្រាប ។

**សត្វទ្វិបាទចតុប្បាទ**– ដូចជាសត្វអស់នេះ គឺរមាស, ដំរី, គោព្រៃ ទិនសេះក្ញុំ មិនដែលឃើញមានទេនៅស្រុកចិន ។ ស្រុក

---

១ មិនគេតែងហាមមិនឲ្យនាំយកគ្រឿងអាហារកើតនៅចេញទៅលក់ប្រទេសក្រៅទេ ទោះ សម័យក្រោយទៀត ក៏អាណាប្រកាមមិនឲ្យនាំស្រូវទៅលក់ប្រទេសក្រៅដែរ ។

នេះសម្បូណ៌ ខ្លាធំ, ខ្លារខិន, ខ្លាឃ្មុំ, ជ្រូកព្រៃ, ក្តាន់, ឈ្លូស, សៀងកា, ស្វាព្រាម, ដែលមានតិចគឺសិង្ហ, ស្វាធំ, ទន្ទ ៗ មិនមានប្រយោជន៍ទេ ផលចេញឈ្មោះ មាន់, ទា, គោ, សេះ, ជ្រូកស្រុក, ចៀម ៗ សេះនោះតូចៗណាស់ គោនោះមានច្រើន ។ អ្នកស្រុកទៀងជិះលើខ្នងគោរស់ តែដល់កស្លាប់ទៅគេមិនស៊ីសាច់មិនពន្ទុះយកស្បែកទេ គេទុកចោលឲ្យពុកផុយរលួយទៅឯង ព្រោះសត្វអស់នេះ គេប្រើកំលាំងក៏ធ្វើការរបស់មនុស្ស ។ គេប្រើគោទឹមរទេះប៉ុណ្ណោះ ។ ពីដើមមកមិនមានក្មានទេ តែតមកពួកអ្នកដើរសមុទ្របាននាំយកសត្វចំពូកនេះមកពីស្រុកចិន ។ ស្រុកនេះមានកណ្ដុរធំៗដូចជាឆ្មា ហើយមានកណ្ដុរមួយពួកទៀតនោះ មានក្បាលដូចក្បាលកូនឆ្កែសុទ្ធតែម្ដង ។

**អំពីចំការបន្លែ-** បន្លែនោះមានខ្ទឹមក្រហមមូតាដ (Moutarcde) ខ្ទឹមស, ត្រប់ស, ផ្សុក, ត្រឡាច, វ៉ង-ក្វា (Wang-Kaua) ហៀន-ឆៃ មិនមានស្ពៃមិនមានសាឡាដ មិនមានសាឡាដម្យ៉ាងទៀត, គ្មានអេ-ពីណាដ៍ (Epinard) ទេ ។ នៅមានបន្លែដទៃៗទៀតជាច្រើន ដែលខ្ញុំមិនស្គាល់ឈ្មោះ ពួកបន្លែទឹកក៏មានចំនួនច្រើនមុខដែរ ។

**អំពីត្រីនិងសត្វលូនវារ-** ចំពួកត្រីនិងអណ្តើក គឺពួកមច្ឆាជាតិទឹកសាបសំបូរនៅមានសំបូណ៌ជាចំផុត ។ ត្រីឆារ-យ ក៏មានសំបូណ៌ណាស់ដែរ មានត្រីខ-ប៊ុ-យោ តូចៗទម្ងន់ជិតពីរលីវ ។ មានចំនួនត្រីជា

ច្រើនទៀតដែលខ្ញុំមិនស្គាល់ឈ្មោះ ។ ពួកត្រីអស់នោះមាននៅក្នុងទន្លេសាបទាំងអស់ ប៉ុន្តែមានប្រភេទជាត្រី សមុទ្រគ្រប់ប្រភេទ មានអន្ទង់ អន្ទង់ទឹកប្រៃ ។ ពួកខ្មែរគេមិនសុីកង្កែបទេ វេលាយប់ទើបឃើញមានពាសពេញនៅលើផ្លូវ ។ អណ្តើកនឹងអីកាន (Iganes) នោះធំៗ ដូចហូ-ជូ ដូចអណ្តើកនៅលៀវ-ឆាង ក៏គេសុីគ្នា ។ បង្កងនៅណា-ណខនោះ ទម្ងន់មួយលីវប្តាំងនោះ ។ ជើងអណ្តើកនៅស្រុកចេន-ពូនោះ មានខ្នាតជល់ទៅ ៨-៩ ពូស ។ មានក្រពើធំៗ ប៉ុនទូកមានជើង ៤ មានលក្ខណៈដូចមង្ករតែឥតស្នែង ពោះក៏មានស្បែកក្រាស់ ស្រុកនោះគាមមិនឃើញមានទេ តែខ្ញុំគិតថាគង់មានដែរ តែពួកស្រុកគេមិនសុីក ។

**គ្រឿងផឹកដែលធ្វើឲ្យបែកពពុះ (ស្រា)**— ស្រានោះមាន ៤ យ៉ាង ទី ១ ហៅតាមចិនថា ស្រាទឹកឃ្មុំ (ម៉ី-តាង-ឈីអៅ (Mi t'angtrieau) គេប្រើមេស្រាជ្រលក់ទឹកឃ្មុំពាក់កណ្តាល ទឹកពាក់កណ្តាល ។ ទី ២ មានឈ្មោះតាមខ្មែរថា ពេង-យ៉ា-ស៊ឺ (Péng-Ya SSeu) គេធ្វើស្រានេះនឹងស្លឹកឈើម្យ៉ាង ។ ពេង-យ៉ាស៊ឺ ជាឈ្មោះស្លឹករបស់ដើមឈើនោះឯង ។ ទី ៣ គេធ្វើនឹងស្រូវឬបាយកកគេហៅថា ប៉ាវ-លេង-គាវ (Pos — léng — kio) ។ នេះជាអង្ករ (ស្រូវ) ។ ចុងក្រោយបង្អស់ជាស្រាស្ករ គេធ្វើនឹងស្ករអំពៅ ។ មួយទៀត កាលណាគេចូលទៅក្នុងទន្លេ ហើយគេទៅតាមដងស្ទឹងនោះ គេផឹក

ស្រាគីយ៉ាវ Kiao ។ មានដើមគីយ៉ាវម្យ៉ាងដុះក្បែរមាត់ទឹក គេយកទៅត្រាំឲ្យបែកពពុះចេញរសជាតិ ។

អំបិល ទឹកខ្មេះ សួយ (Soy) ដំបែ នៅស្រុកខ្មែរ មិនមានកន្លែងទប់ទឹកធ្វើអំបិលទេ ។ នៅបេន-ពូ ទីដទៃឯទៀតៗ ដែលនៅមាត់សមុទ្រ គេទប់ទឹកសមុទ្រសម្រាប់ធ្វើជាអំបិល នៅក្នុងក៏មានធាតុម្យ៉ាងដែលមានរសជាតិគេយកមកប្រើជាអំបិលបាន ។

ពួកអ្នកស្រុកនេះ មិនចេះធ្វើទឹកខ្មេះទេ កាលណាគេត្រូវការទឹកជូរ គេប្រើស្លឹកដើមហៀនពីង (Hien' P'ing) ។ បើដើមឈើមានផ្កាលាស់ត្រួយ គេក៏ប្រើផ្កាត្រួយ បើដើមឈើមានគ្រាប់ គេប្រើគ្រាប់ ។ គេមិនចេះធ្វើសួយទេ ដ្បិតគ្មានស្រូវសាលីនិងសណ្ដែក ។ គេមិនធ្វើដំបែអំពីគ្រាប់ (ធញ្ញជាតិ)ទេ គេធ្វើស្រានិងទឹកឃ្មុំទឹក ហើយនិងស្លឹកឈើ គេចេះប្រើប្រភេទទឹកស្រវឹងមួយយ៉ាងផ្សេងនឹងស្រាសនៅស្រុកយើង ។

អំពីការចិញ្ចឹមដង្កូវនាង— ពួកខ្មែរមិនចិញ្ចឹមដង្កូវសូត្រទេ ហើយពួកស្រីៗក៏មិនចេះដេរទេ គេចេះតែត្បាញសំពត់អម្បោះប៉ុណ្ណោះ ។ ថែមទាំងមិនចេះរវៃអម្បោះនឹងក្រៀងហាត់ ចេះតែរវៃនឹងដៃ ។ ពួកនេះមិនមានរបៀបត្បាញសំពត់ទេ គេចូលចិត្តយកចុងអម្បោះចងចង្កេះ ហើយធ្វើការនិងចុងអម្បោះម្ខាងទៀត ។ ដូចជាត្រល់ មានតែជា

ប៉ាត់ទុសប្រុំប៉ុណ្ណោះ ។ ទើបតែពួកសៀមបានព្យាយាមចិញ្ចឹមនាំឡើង ទើបមានដើមមនទន់ដង្គំនាំមកពីស្រុកសៀម ។

នៅស្រុកនេះមិនមានដើមធ្មេញទេ មានតែដើមលោមា ។ ពួកសៀមចេះត្បាញសូត្រធ្វើជាសំពត់សំបុរពាស់ស្រគាំ (ផាមួង) ។ ពួកសៀមចេះដេរខ្ទឹងបះ ពួកខ្មែរតែកាលណាសំពត់ជាចរហែក គេតែងជួលពួកសៀមឲ្យជួសជុល ។

អំពីគ្រឿងភាជនៈប្រើប្រាស់ – ពួកមនុស្សនៅទកណ្តាលមានផ្ទះ ១ ភ្នំគុ ដើងមាំវែង ធុងទឹក ដើងដាក់ទឹកទេ ។ កន្ការដណ្តាំបាយនោះ គេប្រើឆ្នាំងដី ជាំសម្លគេប្រើខ្ទះដី ។ គេបង្កប់ឬញដុំធ្វើជាជើងក្រាន ហើយយកត្រឡោកដូងធ្វើជាវែក ហានដាក់បាយនោះ គេប្រើចានចិនធ្វើពីដីបុស្តាន់ ។ ភាជនៈសំរាប់ដាក់សម្លនោះ គេយកស្លឹកឈើធ្វើជាចានតូច ។ ទុកជាដាក់ទឹកសម្លពេញក៏មិនលេចដែរ គេយកស្លឹកតើយ៉ាវធ្វើជាស្លាបព្រា សំរាប់ដួសទឹកសម្លហុតឬលក្ខណ៍មាត់ កាលណាបរិភោគរួចហើយ គេក៏បោះចោលអស់ទៅ ។ សម្បក្តុងការសែនបូជាអ្នកតា ឬព្រះពុទ្ធក៏ធ្វើដូចនេះដែរ ។ នៅក្បែរខាងខ្នងគេនោះ មានផ្តិលសំណប៉ាហាំងដាក់ទឹកពេញសំរាប់ជ្រលក់ដៃ គេប្រើតែម្រាមដៃសំរាប់ចាប់បាយបរិភោគ បាយតែងជាប់ម្រាមដៃ បើគ្មានទឹកមុខជាបរិភោគទៅមិនរួចទេ ។ គេផឹកស្រាក្នុងចកប្ញូតែសំណហៅ ពួកអ្នក

ក្រប្រើបកដី ។ នៅផ្ទះអ្នកមានត្រកូលខ្ពស់ឬមានសម្បត្តិនោះ ជួនកាល គេប្រើកាជន៍ប្រាក់ ជួនកាលកាជន៍មាស ។ ក្នុងប្រទេសនេះនៅតំបន់ខ្ពង់-ឆ្នាំគេប្រើកាជន៍មាស ។ មានឆ្លាក់ទង់ទំហំផ្សេងៗ ។ នៅលើដីគេក្រាល កន្ទេល(ស្រកម៉ុង-ចៀរ) ឬស្បែកខ្លា ខ្លាខិន ក្ដាន់ ឈ្លូស ឬកន្ទេលផ្ដៅ ។ គមកបន្តិច គេនិយមប្រើគុតាប ៗ កំពស់ ១ ជើង (៣៣ សម) ។ ឯការដេកនោះ គេប្រើតែកន្ទេលក្រាលដេកលើក្តារ ។ គមកបន្តិច មានប្រើគ្រែតាប ៗ ដែលពួកចិនបានធ្វើឡើង ។ ឯគ្រឿងគុជាក់ថាសពាននោះ គេប្រើគ្របទីងសំពត់ បើ ទៅក្នុងព្រះរាជវាំងព្រះករុណា គេប្រើសំពត់សារប្ដាប់ឱទមាស ជាជំនូនរបស់អ្នកជំនួញប្រទេសក្រៅ ។ ឯស្រូវនោះ គេមិនប្រើថ្លឹងទេ គេប្រើតក្កាល់គិតវិញ ។

អំពីរទេះនិងអង្រឹងស្នែង — អង្រឹងស្នែងនោះ គេធ្វើទងឈើមានសណ្ឋានផតត្រង់ពាក់កណ្ដាល ហើយងើងឡើងនៅចុងទាំងសងខាង ។ គេឆ្លាក់ជាផ្កាភ្ញីផ្សេងៗ ហើយគេបនាដោយមាសឬប្រាក់ ។ នៅចុងម្ខាងៗ នោះគេបោះរន្ធមួយ ហើយយកខ្សែរាក់បង់ខ្នងរន្ធទាំងសងខាង ភ្ជាប់ទីងផ្ទាំងសំពត់ធំ ដែលបត់ជាច្រើនផ្នត់ ។ កាលគេដាក់សំពត់នេះហើយ ទើបប្រើមនុស្សពីរនាក់សែងទៅ ។ គេមានប្រើយានមួយយ៉ាងទៀត មានឆ្លាក់ទូលាយជាងក្តោងទូក ប្រដាប់ប្រដាដោយខ្សែស្បែកពណ៌ផ្សេងៗ ប្រើមនុស្ស ៤ នាក់ឲ្យសែង ។ បើធ្វើដំណើរទៅទីឆ្ងាយ

គេឡើងជិះដំរី សេះ រទេះ ។ ឯរទេះនោះមានសណ្ឋានដូចជាប្រទេស ឯទៀតៗដែរ ។ ឯសេះនោះគ្មានប្រកាន់ទេ ដំរីមិនមានជើងមា សម្រាប់អង្គុយទេ (កែង?) ។

អំពីទូកក្តប-ឃំ —. ទូកធំៗ នោះគេធ្វើនឹងបន្ទះក្តារឈើរឹងៗ ពួកជាងឈើមិនមានរណារធ្វើការតែនឹងពូថៅ ។ ក្តារមួយសន្លឹកៗនោះ អស់ឈើក៏ច្រើនលំបាកក៏ច្រើន ។ បើនឹងធ្វើប្រដាប់អ្វីមួយៗ នោះ គេមិនប្រើពន្លាក ទុកជាសង់ផ្ទះក៏ដោយ ។ ទូកនោះគេប្រើដែកគោល ដែកបោះ ប្រក់ដំបូលនឹងស្លឹកគ្រៀ សសរទល់ទ្រ ប្រើបន្ទះដើមស្លា ។ ទូកបំពួកនេះ គេហៅ ស៊ិន - ណា (Sin-na) ជាទូកប្រើចែវច្រវ៉ា ។ (ទូកនោះ) គេប្រើខ្លាញ់ត្រីលាយនឹងកំបោរបិទ ។ ឯទូកតូចៗនោះ គេធ្វើដោយដើមឈើតាំងដើម គេចោះពុះដើមឈើនោះដូចជាស្នូក ហើយគេយកទៅកំដៅភ្លើងពត់ពង្រីកឲ្យធំពេញទំហំឈើនោះ ។ ទូកបំពួកនេះ ធំទ្បាំងត្រង់កណ្តាលប៉ុណ្ណោះ រៀវចុងរៀវដើម មិនមានក្តោងទេ ចុះ មនុស្សជិះបានជាច្រើន គេប្រើតែចែវច្រវ៉ា គេហៅពី-ឡាន-(P'i-lan) ។.

អំពីភូមិស្រុក —. គ្រប់ៗភូមិតែងមានវត្តឬស្តូប ១ ពោះបើមានអ្នកស្រុកតិច-ច្រើនយ៉ាងណា គេតែងមានអ្នកកាន់ការត្រួតត្រាម្នាក់ដែលគេហៅថា ម៉ៃ-ឈើ (មេស្រុក?) ។ នៅលើផ្លូវធំៗនោះ គេមានទីសម្រាប់សំចត ប្រហែលនឹងទីសំណាក់សេះរបស់យើង ស្ថានទីបែបនេះគេហៅ

ជាសេន-មូ (Sen-mou សាលា ?) ។ ក្នុងពេលដែលកើតចម្បាំងឡើងថ្មីៗ នឹងពួកសៀម ប្រទេសនេះក៏ត្រូវគេបំផ្លាញខ្ទេចខ្ទីអស់ទៅ ។

**អំពីការចាប់យកប្រមាត់**- តាំងពីបុរាណមកហើយ នៅខែទី៨គេតែងចាប់យកប្រមាត់គឺរាល់ៗឆ្នាំ ក្សត្រនៃដែនចម្ប៉ា ទ្រង់មានពាង ១ សម្រាប់ដាក់ប្រមាត់មនុស្សជាចំនួនរាប់ពាន់ប្រមាត់ ។ នៅវេលាយប់គេកំណត់ទីកន្លែងឲ្យពួកមនុស្សជាចំនួនច្រើន នៅក្នុងក្រុងនឹងក្នុងភូមិកាល ណាគេប្រទះឃើញមនុស្សពីក្រៅមកក្នុងវេលាយប់ គេក៏យកថង់គ្របក្បាលដែលមានខ្សែរឹត ហើយមានកាំបិតតូចមួយចោះវះយកប្រមាត់ត្រង់ខាងក្រោមឆ្អឹងជំនីរខាងស្តាំ ។ គេចាំយកប្រមាត់ឲ្យបានចំនួនច្រើនគ្រប់គ្រាន់ ទើបយកទៅថ្វាយស្តេចចម្ប៉ា ។ ប៉ុន្តែប្រមាត់ជាតិចិនគេមិនយកទេ ដ្បិតមានកាលមួយឆ្នាំនោះ គេយកបានប្រមាត់ចិនម្នាក់ ដាក់លាយជាមួយនឹងអ្នកឯទៀតៗ រួចតមកប្រមាត់នៅក្នុងពាងក៏ស្អុយយកទៅប្រើការពុំបាន ។ ទើបតែឥឡូវនេះឯង គេលើកលែងទំនៀមទម្លាប់នេះ ប៉ុន្តែនៅមានមន្ត្រីដែលចាប់យកប្រមាត់ ដែលនៅក្នុងក្រុងជិតទ្វារខាងជើង ។

**អំពីមនុស្សប្លែក** -. នៅក្នុងក្រុងនោះ ត្រង់ខាងទ្វារទិសខាងកើត មានមនុស្សព្រៃមួយ (មន - ជេន = man-jen) ដែលបានទៅសេពសម្ភពជាមួយនឹងប្អូនស្រីរបស់ខ្លួន ។ ខ្លួនរបស់បុរសស្ត្រីទាំងពីរ

ក៏ជាប់គ្នាទៅ លុះតមក ៣ ថ្ងៃ ក៏អត់អាហារស្លាប់ទៅទាំងពីរនាក់ ។ ឈ្មោះអ៊ីជាមនុស្សជាតិជាមួយនឹងខ្ញុំ ដែលបាននៅក្នុងប្រទេសនោះមក ៣៥ ឆ្នាំហើយ ក៏បាននិយាយថា បានឃើញហេតុកេរនេះពីរដងមកហើយ ។ ហេតុអស់នេះកើតមកតែអំពីការអស្ចារ្យរបស់ព្រះពុទ្ធជាម្ចាស់ ។

អំពីការងូតទឹក — ក្នុងប្រទេសនេះក្តៅណាស់ ទើបគេមិនដែលខានងូតទឹក ក្នុងមួយថ្ងៃៗ ជាច្រើនដងទេ ។ សូម្បីក្នុងវេលាយប់ ក៏គេមិនដែលខានងូតទឹកមួយដងឬពីរដងដែរ ។ តាំងពីដើមមកនោះ មិនមានផ្ទះសម្រាប់ងូតទឹក មិនមានអាងងូតទឹក ។ ក្នុងមួយស្រុកៗ តែងមានថាំងទឹក (ទីថាំងទឹក = Bassin) ពីរឬបីគ្រាមានថាំងទឹកមួយរមែង ទាំងប្រុសទាំងស្រីចូលងូតស្រាតទាំងអស់គ្នាក្នុងថាំងទឹកនោះ លើកលែងតែមានអាពុកម្ដាយ ឬមនុស្សចាស់ៗ នៅក្នុងថាំងនោះ ទើបកូនប្រុសកូនស្រីប្អូនក្នុងក្រមុំកំឡោះមិនចូលទៅងូត ។ ប្រសិនបើក្នុងក្រមុំកំឡោះងូតក្នុងថាំង ពួកចាស់ៗ ក៏គេចចៀសចេញដែរ ។ ប៉ុន្តែបើមនុស្សមានអាយុស្រករក្នុងមិនជាការទាស់ទេ ។ គេយកដៃឆ្វេងបិទគ្របកេរកំណើតរបស់ខ្លួនហើយដើរចូលទៅក្នុងទឹក ត្រៀតជ្រះគ្រប់គ្នា ។ គ្រប់ៗ បីឬបួន ៥ ឬ ៦ ថ្ងៃ ពួកស្រីៗ នៅក្នុងក្រុង រួមគ្នាជាពួកៗ ខាង ៣ ដល់ ៤ ទូក នាំគ្នាចេញទៅងូតទឹកក្នុងទន្លេក្រៅក្រុង ។ លុះដល់ទៅមាត់ទន្លេ ស្រីអស់នោះក៏ដោះសំពត់ស្បៀកពាក់ចេញ ហើយដើរចូលទៅក្នុង

ទឹក ៗ គេតែងទៅជួបជុំគ្នាក្នុងទន្លេទាំងពាន់ៗនាក់ ៗ សូម្បីស្រីដែលមានត្រកូលខ្ពស់ ក៏ទៅសប្បាយក្នុងទន្លេមិនមានអៀនខ្មាសឡើយ ៗ អ្នកកាលគ្នាអាចមើលឃើញស្រីទាំងនោះ តាំងពីក្បាលរហូតដល់ជើង ៗ ឯក្នុងទន្លេធំនោះនៅក្រៅក្រុង មិនមានថ្ងៃណាទំនេរមនុស្សចុះទឹកទេ ៗ នៅថ្ងៃទំនេរ ពួកចិនច្រើនតែនាំគ្នាទៅយកខ្យល់អាកាសឯទន្លេនោះដែរ ៗ ឯទឹកនោះក្តៅជានិច្ច ដូចគេដាក់ដាំលើភ្លើង លុះតែដល់យាមទី៥ ទើបត្រជាក់ត្រាន់បន្តិច ប៉ុន្តែដល់ថ្ងៃរះឡើងត្រឡប់ក្តៅឡើងវិញ ៗ

**អំពីពួកមនុស្សដែលចេញពីស្រុកទៅ** — . ពួកចិនដែលរកស៊ីខាងជើងទឹក តែងឆ្លៀតយកចំណេញដែលខ្លួនមកនៅក្នុងប្រទេសនោះ ដើម្បីមិនបាច់ស្លៀកពាក់សំពត់អាវ ៗ (នៅស្រុកនោះ) ស្រូវអង្ករងាយរក ស្រីៗក៏ងាយនឹងបានជួបប្រទះ, ផ្ទះក៏ងាយនឹងតាក់តែងធ្វើ, គ្រឿងប្រដាប់ផ្ទះក៏ងាយរកទិញ, ជំនួញក៏ងាយលក់ដូរ ៗ ហេតុនេះហើយទើបមានពួកចិនចូលទៅនៅក្នុងស្រុកនោះជារឿយៗមក ៗ

**អំពីគ្រឿងអាវុធ** — . ពួកកងទ័ពទៅតែខ្លួនទទេជើងទទេ ដៃស្តាំកាន់លំពែង ដៃឆ្វេងកាន់ខែល ៗ ពួកខ្មែរគ្មានធ្នូ គ្មានព្រួញ គ្មានគ្រឿងផ្ទាត់គ្រាប់ គ្មានគ្រាប់កាំភ្លើងធំ គ្មានអាវក្រោះ គ្មានមួកដែកទេ ៗ គេនិយាយថា ក្នុងការច្បាំងជាមួយនឹងសៀមនោះ

ដេញបានកេណ្ឌពស្រុកទាំងអស់ចេញទៅច្បាំង តែមិនប្រើឧបាយកល មិនមានយុទ្ធវិធីទេ ។

អំពីមហាក្សត្រស្តេចចេញ—. ខ្ញុំបាននៅក្នុងប្រទេសនោះជាវេលាជាង ១ ឆ្នាំ ហើយខ្ញុំបានឃើញស្តេចចេញដល់ ៤ ឬ ៥ ដង ។ កាលណាស្តេចចេញនោះ មានកងទាហានសេះកិត្តិយសនៅក្បាល, រួចបន្ទាប់មកពួកទង់ជ័យធំ-តូច, ពួកទង់ជ័យភ្លេង ។ ពួកកុមារីក្នុងវាំងមានចំនួនពី ៣០០ ដល់ ៥០០ នាក់ ស្លៀកពាក់សំពត់ក្បាច់ផ្កា សក់ពាក់ផ្កាផ្សេងៗ កាន់ទៀនធំៗ ហើយរួមគ្នាជាក្រុមមួយ ទុកជាក្នុងវេលាថ្ងៃក៏អុជទៀនគោលទាំងនោះដែរ ។ រួចបន្ទាប់មក ពួកកុមារីក្នុងវាំងកាន់គ្រឿងក្រដូបគោកជាមាសនិងប្រាក់ និងគ្រឿងប្រដាប់ប្រដាផ្សេងៗទៀត មានបែបសណ្ឋានផ្សេងៗគ្នា ជាទំនៀមទម្លាប់ដែលខ្ញុំមិនបានដឹងសព្វគ្រប់ទេ ។ តមកទៀត ទើបដល់ពួកកុមារីក្នុងវាំងកាន់លំពែងនិងខែល ដែលជាកងរក្សាព្រះមន្ទីរព្រះមហាក្សត្រ ពួកនេះក៏រួមគ្នាជាក្រុមកងមួយដែរ ។ បន្ទាប់ទៅទៀត ទើបពួករទេះទឹមពពែ រទេះទឹមសេះ ជំប្រដាប់ប្រដាដោយមាស ។ ពួកសេនាបតី ពួកព្រះអង្គម្ចាស់ ឡើងជិះដំរីផងដោយក្លស់ក្រហមព្រាលច្រើនរាប់មិនអស់ ។ នៅក្រោយពួកនេះ ទើបដល់ព្រះអគ្គមហេសី និងស្រីព្រះស្នំរបស់ព្រះមហាក្សត្រ ជិះអង្រឹងស្នែង, រទេះ, ដំរី ។ ពួកនេះ ក៏មានក្លស់ច្រើនរាប់រយបាំង

មាសតាំងអស់ នៅខាងក្រោយនេះទើបដល់ព្រះមហាក្សត្រ ទ្រង់ស្ដេក ឈរនៅលើដំរីមួយ ព្រះហស្ដទ្រង់ព្រះខ័ន ។ ឯក្ងុកដំរីនេះសឹងស្រោបមាសតាំងសងខាង មានព្រះក្លស់សយ៉ាងថ្លៃប្រដាប់មាសបើកបាំង ហើយមានដំរីជាច្រើនហែមកេម ទឹងកងពាហានសេះការពារក្បព្រះអង្គ ។ ប្រសិនបើស្ដេចយាងទៅទីជិតៗទេ គេប្រើព្រះសាលៀងមាសមួយ កុមារីកងរ៉ាំង ៤ នាក់សែង ។ ព្រះមហាក្សត្រស្ដេចចេញជាញឹកញយណាស់ ដើម្បីទៅទតព្រះនេត្រចេតិយមាសតូចមួយនៅខាងមុខចេតិយនេះ មានព្រះពុទ្ធរូបមាសមួយព្រះអង្គ ។ ពួកអ្នកដែលបានក្រឡេកឃើញព្រះរាជា ត្រូវតែឱនក្រាបថ្វាយបង្គំថ្ងាសដល់ដី គេហៅថា សន—ប៉ា (សំពះ= (San-Pa) ។ បើមិនធ្វើដូច្នេះទេ នឹងត្រូវមេព្រះពជពិធី (តម្រួតរាំង?) ចាប់ខ្លួនធ្វើទុក្ខទោសពុំដែលខានឡើយ ។

ព្រះមហាក្សត្រស្ដេចប្កានរេងព្រះតំនាល់ពីរដងរាល់ៗថ្ងៃ ទ្រង់ពិនិត្យកិច្ចរាជការ ។ នៅទីនោះ មិនមានបញ្ជីរាយឈ្មោះប្រកាសទុកទេ ។ ពួកអ្នករាជការក្ដី បណ្ដាស្ដ្រីក្ដី ដែលចង់ឃើញព្រះរាជាក៏អង្គុយនៅនឹងដីចាំមើល ។ គង់មួយស្របក់តមកគេបានឮស្នូរភ្លេងល្វើយៗពីក្នុងវាំងមក ហើយនៅខាងក្រៅវាំងគេផ្លុំខ្យងស័ង្ខប្រាប់ឲ្យដឹងដំណើរស្ដេចយាងមក ។ ខ្ញុំបានឮគេនិយាយប្រាប់ថា បើមិនស្ដេចយាងទៅទីឆ្ងាយទេ គេប្រើតែព្រះសាលៀងមាសមួយប៉ុណ្ណោះ ។ តមកបន្តិច

គេមើលឃើញកុមារីក្មេងកំពីរនាក់ ចាប់បើកសើយព្រះសន្ទ្យា ឡើងដោយម្រាមដៃរៀវៗ ហើយព្រះករជាព្រះហស្ដទ្រង់ព្រះខ័ន ត្រង់បន្ទោះសហាបញ្ចូរមាស ។ ពួកសេនាបតីទាំងបណ្ដារាស្ដ្រ ក៏ប្រណម្យអញ្ជលីថ្វាយបង្គំ កាលផុតសូរសព្ទស្លេងស័ង្ខ ទើបគេនាំគ្នាក្រោកឡើង ហើយគេនាំគ្នាចូលទៅអន្ទុយគាល់ ។ ត្រង់ទីដែលព្រះមហាក្សត្រគង់នោះ ជាស្បែកសិង្ហដែលគេរក្សាទុកជាព្រះរាជទ្រព្យ ។ កាលណាចប់កិច្ចរាជការហើយ ទើបព្រះមហាក្សត្រស្ដេចត្រឡប់វិលវិញ កុមារីពីរនាក់ក៏ទំលាក់សន្ទ្យា អ្នកទាំងអស់គ្នាក៏នាំគ្នាក្រោកឡើង ។

ចប់

---

# រឿងចៅកាំបិតបន្ទោះ

(តមក)

ឯចៅប្រុសក៏ចំដើរដោយអំណាចកែវ ផ្លូវដើរចម្ងាយ ៧ យប់ ចៅប្រុសដើរតែ ១ ថ្ងៃពេលព្រលប់ក៏បានដល់ទៅផ្ទះរបស់ខ្លួន ។

ក៏ចៅប្រុសទៅដល់ផ្ទះស្រែកហៅប្រពន្ធថា នាងអើយនាង បើកទ្វារឲ្យបងផងបងមកដល់ហើយ ឯមេប្រពន្ធជាស្រីអាក្រក់ក្បត់ចិត្តប្ដីដេកទបសហាយញីមាត់ប្ដីហៅធ្វើជាថាអ្នកណាហៅអី ប្ដីអញមិននៅកុំមកហៅ ចៅប្រុសឮប្រពន្ធថាដូច្នោះទើបថាប្រពន្ធចិត្តត្រង់នឹងខ្លួន ក៏ឆ្លើយទៅថា ទេបងទេតើនាង មេប្រពន្ធថា បើអ្នកទេឬ ខ្ញុំគិតថាជាមនុស្សទាំងផ្ដាសកាច់ឥតហៅខ្ញុំ ហើយមេនោះក៏ថា អ្នកចាំខ្ញុំអុជចន្លុះសិនតែក៏បណ្ដោះសហាយក៏សោះ ឯចៅប្រុសក៏យកបបដីកដីក្រោមមាត់ជណ្ដើរ ហើយកប់កែវនឹងខ្សែចងដំបងតាំងឆ្អឹនឯងរួចលុបដីទៅ មេនោះបណ្ដោះសហាយក៏រួច ក៏អុជចន្លុះចុះមកទទួលប្ដីឡើងទៅលើផ្ទះ រៀបបាយទឹកឲ្យប្ដីស៊ីរួចក៏នាំប្ដីចូលដេក ។

ដេកហើយក៏និយាយសួរថា អ្នកទៅស្រុកចិនបានអីមកផ្ញើខ្ញុំខ្លះ ចៅប្រុសជាប្ដីប្រាប់ទៅប្រពន្ធថា បងគ្មានបានអីទេ បងគេឲ្យនោមួយហើយនឹងដាវឧបមួយក្បៀង មេនោះធ្វើជាយំស្រែកថាមិនមែនទេអ្នកកុហកខ្ញុំទេ មិនផលទរណាទៅដល់បងហើយគេទានដល់មុងក៏នឹងឲ្យដាំដុប

ៗ ក្បួនទាំមួយដូច្នោះ ឯចៅប្រុសនឹកដល់ពាក្យដែលគ្រូផ្តាំ ថាចូលដំ-ណេកកុំនិយាយនឹងប្រពន្ធឯង ចៅប្រុសនោះថា ណើយនាងចាំព្រឹកសឹមបងប្រាប់ ឯតាសហាយមេស្រីនោះលបស្តាប់ពីក្រោមផ្ទះនោះបានឮទាំងអស់ ហើយមេនោះក៏ទទូចសួរប្តីទៀត ចៅប្រុសនោះនឹកគិតថា ប្រពន្ធចិត្តស្មោះត្រង់នឹងខ្លួនទីកអាករភ័គ ប្រពន្ធណា សំនឹងប្រាប់ក្រែងខុសនឹងបណ្តាំគ្រូ ឯមេនោះក៏ចេះតែទទូចសួរណាស់ ចៅប្រុសក៏ភ្លេចបណ្តាំគ្រូ ទើបប្រាប់ថា គ្មានបានអីទេ បានតែកែវជ្រូក ១ ខ្សែចងឯង ដំបងវាយឯង ឆ្នាំងឆ្អិនឯងពុំណើង ឯមេនោះទទូចសួរតទៅទៀតថា ចុះរបស់អស់នោះទុកនៅឯណា ចៅប្រុសយល់ឃើញថាយប់នោះស្ងាត់មនុស្សម្នាដេកលក់អស់ហើយ មិនបានដឹងថាសហាយមេប្រពន្ធនោះពួននៅក្រោមផ្ទះ ក៏ប្រាប់ប្រពន្ធថា បងកប់នៅក្រោមមាត់ជណ្តើរ ឯមេនោះក៏ថាឲ្យឮខ្លាំងៗថា យើអើបានកែវជ្រូក ១ ខ្សែចងដំបងវាយឯងឆ្នាំងឆ្អិនឯង យើហើន យកទៅកប់នៅក្រោមជណ្តើរមុខផ្ទះ ឯតាសហាយឮថាដូច្នោះ ក៏រំមកគាស់យកអស់ទៅ ឯចៅប្រុសនោះនឹងមេប្រពន្ធក៏នាំគ្នាដេកលក់ទៅ ។

លុះព្រឹកព្រហ្មឡើង ចៅប្រុសនោះទៅរករបស់នោះបាត់អស់ ឃើញតែស្នាមកកាយ ក៏ចៅប្រុសនោះផ្ញើឃ្លាំងដាក់ជណ្តើរ យកខ្សែចងខួសទៅប្តឹងចៅក្រមសាលា ១ ក៏ទទួលជំរះ រាយជណ្តើរពិចារណាសួរថាជណ្តើរឯងទទួលបញ្ចូលចៅប្រុសនេះ ម៉េចក៏ឯងឲ្យមនុស្សលួចរបស់

គេអស់ ឯចៅក្រមក៏ហេតុតែជាអ្នកឥតប្រាជ្ញាមិនយល់ការអាថ៌កំជ្រៅ ក៏បបួលគ្នាសើចនឹងជណ្ដើរមិនស្ដី ហើយស្ដីទៅចៅបុរសនាំបង្កើតក្ដីថា ចៅឯងឆ្កួត ដីដូនដីតាអាណាគេក្ដីនឹងជណ្ដើរដូចចៅឯងនេះ ចៅឯងទៅរកអ្នកឯណាឲ្យគេជំរះឲ្យចៅឯងចុះ ។

ឯចៅបុរសនោះបង់ជណ្ដើរស្ទុះចូលទៅក្នុងវាំង ចួនជាស្ដេចចេញគង់ព្រះពន្លាគាល់ក៏ស្ដេចទតឃើញ ទើបស្ដេចឲ្យអាមាត្យទៅហៅចៅបុរសនោះមក ស្ដេចមានព្រះបន្ទូលសួរថា ចៅបុរសឯងមានរឿងដូចម្ដេច ក៏បានជាដាក់ឃ្នងជណ្ដើរហើយបង់អូសដួលគេពីដំណើរហេតុអ្វី ចៅបុរសនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស កាលដើមឡើយទូលបង្គំជាខ្ញុំបានយករបស់ទៅដាក់កប់ក្រោមជណ្ដើរនេះ ផ្ញើនឹងជណ្ដើរឲ្យរក្សាឲ្យ ជណ្ដើរនេះឲ្យមនុស្សលួចយកអស់. បានជាទូលបង្គំជាខ្ញុំពុំសុខចិត្តនឹងជណ្ដើរ ។

ឯស្ដេចមានព្រះបន្ទូលសួរចៅបុរសថា របស់អ្វីខ្លះ ចៅបុរសនោះក្រាបទូលថា ខ្សែចង ដំបងកាយ ឆ្នាំងផ្ចិនឯង កែវប្រកដេរលើទឹកបាន ស្ដេចទ្រង់ជ្រាបហើយ ស្ដេចឲ្យបុរសយកជណ្ដើរនោះមកថ្វាយស្ដេច ។ ឲ្យអាមាត្យយកទៅទុក ស្ដេចទ្រង់ល្បងដោយព្រះប្រាជ្ញា ។ ស្ដេចមានបន្ទូលថា ចៅបុរសប្រពន្ធចៅឯងមានសហាយ ចៅឯងនៅនឹងអញចុះ ក៏ស្ដេចទ្រង់ព្រះរាជទានសំពត់អាវឲ្យបុរសនោះស្លៀកពាក់ ឯចៅបុរស

នោះក៏នៅគាល់បំរើស្តេចប្រមាណ ៣ ថ្ងៃ ស្តេចទ្រង់ព្រះពជទានព្រះពស្ត្រកូសាឲ្យចៅប្រុសហើយស្តេចផ្តាំថា ចូរចៅឯងយកសំពត់នេះទៅផ្ទះចៅចុះ បើមានគេទៅប្រាប់ថាឲ្យមកមើលរបាំ ឯងកុំមក ឯងឲ្យតែសំពត់អស់ទាំងនេះទៅប្រពន្ធឯងស្លៀកពាក់មកមើលរបាំ ចៅប្រុសនោះព្រួស្តេចផ្តាំស្រេចហើយ ក៏ថ្វាយបង្គំលាស្តេចវិលទៅផ្ទះវិញ ។

ឯមេប្រពន្ធឃើញប្តីបានសំពត់ល្អ ត្រេកអរពេកជួបស្រឡាញ់ប្តីនោះណាស់ លុះព្រឹកឡើងស្តេចឲ្យប៉ាវគងប្រាប់ឲ្យអស់បណ្តាប្រជា-នុរាស្ត្រទាំងអស់ទៅមើលរាំ ព្រោះស្តេចរៀបរាំឲ្យគេសាកស្ត្រីមើល ឯអស់អ្នកស្រុកក៏បបួលគ្នាទៅមើលល្ខោនទេហ៊ឹងអឺងកង មេប្រពន្ធចៅប្រុសនោះក៏បបួលថា អ្នកទៅមើលរាំទីនេះទេ ឯចៅប្រុសថា នាងឯងទៅមើលចុះ យកសំពត់ឯណោះទៅស្លៀកមើលរាំទីនេះចុះ ។

មេនោះព្រួប្តីឲ្យសំពត់ល្អយកទៅស្លៀកមើលរាំ ក៏នឹកអរក្នុងចិត្តគិតយកទៅឲ្យសហាយនោះស្លៀកផង ព្រោះប្តីមិនទៅមើលទេ ក៏មេនោះហេះលាំងបានសំពត់នោះចុះដើរទៅស្កាត់កេសហាយឃើញហើយក៏ឲ្យសំពត់នោះទៅអាសហាយស្លៀក រួចបណ្តើរគ្នាទៅដល់ទីរាំងចូលទៅឈរមើលល្ខោនទន្ទឹមគ្នា ។

ឯស្តេចឲ្យទាហានត្រួតពិនិត្យមើល បើឃើញនរណាស្លៀកសំពត់នេះស្តេចប្រទានឲ្យចៅប្រុសនោះ ស្តេចឲ្យចាប់មកទាំងប្រុស

តាំងស្រី អស់ពួកទាហានក្រុមកាំងល្បាតទៅឃើញតានោះមេនោះ ឈរមើលកាំទន្ទឹមគ្នា ក៏ទាហានក្រុមកាំង ហៅតានោះមេនោះមកថ្វាយស្តេចៗទតទៅមិនមែនខ្លួនចៅប្រុស ស្តេចឲ្យទៅហៅចៅប្រុសនោះមកស្តេចត្រាស់សួរថា ឯណាប្រពន្ធចៅប្រុសឯង ចៅប្រុសនោះក្រាបទូលថាសូមទ្រង់ព្រះមេត្តាប្រោសនាងនេះហើយជាប្រពន្ធទូលបង្គំជាខ្ញុំ ហើយស្តេចមានបន្ទូលថា ចុះចៅនេះឯងស្គាល់ទេ ចៅប្រុសក្រាបទូលស្តេចថាមិនស្គាល់ទេ ទើបស្តេចឲ្យយកកន្ទបកញ្ចាស់មកឲ្យតាសហាយមេនោះផ្លាស់សំពត់នោះចេញ ហើយស្តេចត្រាស់សួរថា សំពត់នេះឯងបានមកពីណា តានោះភិតភ័យក្រាបទូលស្តេចថា នាងនេះឲ្យទូលបង្គំស្លៀកស្តេចសួរថា តាឯងលួចប្រពន្ធចៅប្រុសនេះមែនឬទេ តានោះក៏ទូលស្តេចថា ទូលបង្គំលួចមែន ហើយស្តេចត្រាស់សួរថា របស់ដែលចៅប្រុសនេះគេកប់ទុកក្រោមដំណេករឯងលួចយកទៅមែនឬទេ តានោះទូលថាទូលបង្គំលួចយកមែន ហើយស្តេចឲ្យបណ្តើរតានោះទៅយករបស់អស់ទាំងនោះមក ។

តអំពីនោះ ស្តេចមានព្រះបន្ទូលសួរចៅប្រុសនោះថា របស់នេះហើយឬជារបស់ប្រពន្ធឯង ឯចៅប្រុសក្រាបទូលថា របស់អស់នេះហើយជារបស់ទូលបង្គំជាខ្ញុំ ហើយស្តេចត្រាស់សួរថា ឯតានេះនិងមេនេះ នឹងឲ្យធ្វើទោសយ៉ាងណា ចៅប្រុសនោះទូលថាទូលបង្គំជាខ្ញុំសូម

ព្រះរាជទានទោសឲ្យវាយក្នាក់ទៅចុះ ឯស្តេចនឹងនាម៉ឺនក៏គោរពចិត្តចៅបុរសនោះស្តេចក៏ឲ្យដោះលែងតាមពាក្យចៅបុរសនោះ ហើយចៅបុរសលើករបស់ទាំងអស់ថ្វាយទៅស្តេច ក្រាបទូលស្តេចថា សូមទ្រង់ព្រះមេត្តាប្រោស ឯខ្សែនឹងដំបងនេះបើមានសត្រូវជាបច្ចាមិត្រមក បើខ្សែឲ្យទៅចងដំបងវាយក៏បច្ចាមិត្រនោះស្លាប់វិនាសអន្តរាយអស់ ឯឆ្នាំងនេះបើទ្រង់សព្វព្រះទ័យនឹងព្រះក្រយាស្ងោយវិសេសណា ក៏ប្រាប់ថាឆ្នាំងជូនឡើងក៏ជូនបានដូចចិត្ត តែប្រដាក់នេះទៀតបើទ្រង់សព្វព្រះទ័យយានលើទឹកក៏បាន ៗ ឯស្តេចនឹកក្នុងព្រះទ័យថា ទ្រព្យទាំងនេះជាទ្រព្យមានដម្លៃអញនឹងឲ្យទ្រព្យអ្វីឲ្យជូនល្មមនឹងថ្លៃរបស់ចៅបុរសនេះគ្មាន ទុកជាខ្លួនអញនឹងមហេសីបុត្រី ទាំងព្រះរាជទ្រព្យទាំងនគរក្តីក៏ពុំស្មើដំឡៃរបស់ចៅបុរសនេះឡើយ ។

ទើបមហាក្សត្រស្តេចមានព្រះបន្ទូលទៅនឹងចៅបុរសថា របស់អញគ្មានអ្វីនឹងតបថ្លៃទ្រព្យចៅបុរសឯងទេ អញមានតែបុត្រីមួយនឹងរាជសម្បត្តិ អញលើកឲ្យតបថ្លៃទ្រព្យចៅ ឯចៅបុរសក្រាបទូលទៅវិញថា សូមទ្រង់ព្រះមេត្តាប្រោស ទូលបង្គំជាខ្ញុំជាមនុស្សកំសត់ពុំប្រាថ្នារាជសម្បត្តិ នឹងព្រះរាជបុត្រីល្អិតចូលព្រះបាទទេ បើទ្រង់ព្រះមេត្តាប្រោសសូមព្រះរាជទានតែកាំបិតបន្ទោះមួយ ស្តេចទ្រង់ជ្រាបគ្រប់ប្រការដូច្នោះហើយ ស្តេចមានបន្ទូលឲ្យជាងយកដែក ១០ ហាបទៅវាយដំធ្វើជាកាំបិត

បន្ទោះមួយ ឯកាំបិតបន្ទោះនោះទុកជាយកក្តារមកដាក់តម្រួតគ្នាជា ៧ ជាន់ គ្រាន់តែគូសជាចម័នដ័ន ទើបស្ដេចឲ្យធ្វើស្រោមដាក់ ហើយស្ដេចទ្រង់ព្រះរាជទានឲ្យចៅបុរសនោះ ឯចៅបុរសនោះក៏ថ្វាយបង្គំលាស្ដេចទៅ ។

អស់នាម៉ឺនទីនគរស្ដេចក៏គេនិយាយគ្នាថា ចៅបុរសនេះជាមនុស្សឥតសំណាង ស្ដេចឲ្យបុត្រីឲ្យរាជសម្បត្តិមិនយក ទៅយកឯកាំបិតបន្ទោះដងមួយ ហើយបន្ទូលឲ្យហៅតែចៅកាំបិតបន្ទោះដងមួយតាំងអំពីកាលនោះមក ។

ឯចៅកាំបិតបន្ទោះដងមួយក៏បេះតែដើរទៅៗ ទៅដល់នគរស្ដេចមួយអង្គទៀត ក៏ចូលទៅសុំសំណាក់នៅផ្ទះមហាសេដ្ឋី ឯសេដ្ឋីនោះមានកូនស្រីមួយគ្មានកូនប្រុសសោះ បានឃើញចៅកាំបិតបន្ទោះដងមួយមកសុំសំណាក់ដូច្នោះក៏មានចិត្តស្រឡាញ់អាណិតឲ្យនៅសុំធ្វើជាកូន ចៅកាំបិតបន្ទោះដងមួយតាំងពីបានមហាសេដ្ឋីធ្វើជាអាពុកធម៌ថ្ងៃណា ក៏តែងតែថែទាំជាសង្កៀនខ្ញុំកំដរឲ្យធ្វើការរកស៊ី មិនមានឲ្យមហាសេដ្ឋីព្រួយចិត្តឡើយ ឯមហាសេដ្ឋីក៏មានចិត្តអាណិតស្រឡាញ់ចៅកាំបិតបន្ទោះដងមួយលើសកូនបង្កើតពោះទៅទៀត ។

ដូនជាស្ដេចនោះទ្រង់ចង់ពិសោធរករើសនាម៉ឺនណាដែលមានចំណេះប្រាជ្ញាចេះរក្សាទឹកដីជូនស្ដេចបាន ទើបទ្រង់ឲ្យរៀបទីព្រះខ័នក្រាលព្រំតែព្រំព្រំរៀបចំ ហើយរៀបសម្រាប់ដាក់គោជនបំណី ទើបមន្ត្រីណា

ត្រូវវេនក៏ឲ្យទៅស៊ីដេកចាំកន្លែងជាសម្រាប់រៀងទៅ  ក៏អស់នាម៉ឺនតែងតែ ទៅស៊ីចំណីនោះហើយដេកនៅទីព្រះខែននោះ  ស្ដេចលបចេញមក មើលឃើញដេកពុំភ្ញាក់ ក៏ស្ដេចឲ្យដាស់ឡើងឲ្យចាប់យកទៅកាប់ទៅ តែ ត្រូវនាម៉ឺនណាដេកវេននាម៉ឺននោះស្លាប់  ស្ដេចពិសោធអស់នាម៉ឺនសម្លាប់ ស្លាប់អស់ក្រៃល ។

លុះដល់វេនសេដ្ឋី ៗ ក៏ឲ្យប្រពន្ធរៀបរណ្ដាប់ធ្វើបុណ្យខ្វូនទឹកថាតែ ទៅដេកវេនហើយមិនដែលអ្នកណារស់រួចមួយ  អស់ប្រពន្ធកូនបងប្អូន ញាតិសន្ដានខ្ញុំកំដរគេយំទ្រហឹងអឹងកង  ឯសេដ្ឋីដេកសន្លឹកសន្លៃអាហារ ចំណីក៏ពុំបរិភោគ ។

ចៅកាំបិតបន្ទោះដងមួយឮគេយំរលំគ្នា  ក៏ចូលទៅសួរមហាសេដ្ឋី ឃើញតាពុកដេកសន្លឹកសន្លៃអត់អាហារចំណីដូច្នោះក៏សួរថា  អ្នកតាពុក ហេតុអ្វីក៏គេយំទ្រហឹងអឹងកង  ហើយអ្នកតាពុកសម្រាន្តសន្លឹកសន្លៃអា- ហារចំណីពុំបរិភោគ  នេះតើមានការណ៍ហេតុអ្វី  ចូរអ្នកតាពុកប្រាប់ឲ្យខ្ញុំ បាទដឹងផង  ឯមហាសេដ្ឋីឮចៅកាំបិតបន្ទោះដងមួយសួរដូច្នោះក៏ប្រាប់ថា ចៅតូចអើយ  តាពុកបានអ្នកមកធ្វើគុនថ្ងៃណា  តាពុកគ្មានទាស់ចិត្តពីការអ្វី តាពុកនឹកថានឹងបាននៅក្បែរកូននឹងចៅទុកបង្រៀនអ្នកឲ្យរៀនសួនតាពុក  ជំនួស តាពុកបានខ្វល់សេចក្ដីស្លាប់វេលាល្ងាចនេះហើយ  ដ្បិតស្ដេចឲ្យទៅដេក

ចាំកាំង តែនាម៉ឺនណាទៅដេកក៏ស្លាប់ពុំលែង បើអត់ពីអាពុកទៅ ចូរកូន អ្នកនៅរក្សាម្តាយនិងប្អូនស្រីផងណា ។

ឯចៅកាំបិតបន្ទោះដងមួយឮអាពុកនិយាយប្រាប់ដូច្នោះក៏ជំរាបទៅ អាពុកថា អ្នកអាពុកក្រោកឡើងពីសាក្រយាទៅកុំព្រួយ ឯការត្រង់ ដេកចាំកាំងអ្នកអាពុកកុំថប់ ទុកធុរៈឲ្យខ្ញុំទៅដេកឲ្យស្លាប់ជំនួសអ្នកអាពុក ឯមហាសេដ្ឋីថា ណ្ហើយខ្លួនកូនអ្នកនៅក្មេង ខ្លួនអាពុកចាស់ហើយ ក៏ល្មមស្លាប់ដែរ ចៅកាំបិតបន្ទោះដងមួយជំរាបមហាសេដ្ឋីជាអាពុកថា អ្នកអាពុក ឯដេកចាំកាំងនេះតែអ្នកណាទៅដេកហើយមិនដឹងកលក៏ស្លាប់ បើដឹងកលដូចជាខ្លួនខ្ញុំបាទនេះមិនស្លាប់ទេ ប៉ុន្តែនាម៉ឺនទាំងអស់ដែល ស្លាប់ទៅនោះសុទ្ធតែគ្មានដឹងកលកិច្ចអ្វីសោះបានជាស្លាប់ ខាងតែខ្លួន ខ្ញុំទើបដឹងកលស្តេចនេះ ។

មហាសេដ្ឋីឮចៅកាំបិតបន្ទោះដងមួយនិយាយដូច្នោះក៏ក្រោកឡើង ស៊ីបាយនិងទឹក លុះដល់ល្ងាចចៅកាំបិតបន្ទោះដងមួយ ក៏កាន់កាំបិត បន្ទោះចុះដើរទៅដល់កាំង អស់ពួកព្រះក្រឡាកិច្ចប្រគល់របស់ដែលរៀប បម្រុងទុកនោះឲ្យចៅកាំបិតបន្ទោះដងមួយ ចៅកាំបិតបន្ទោះដងមួយ មកនឹកគិតថា ស្តេចនេះនឹងចង់រើសរកនាម៉ឺនណាដែលមានគំនិត ល្អបេះរក្សាទឹកដីបានជាស្តេចនេះតាំងពិសោធយ៉ាងនេះហើយចៅកាំបិត បន្ទោះក៏ពុំដេកថយទៅអង្គុយចម្ងាយពីទីនោះពីរព្យាម ។

លុះយប់អធ្រាត្រស្ងាត់ស្តេចចេញក្លែងភេទដើរទៅ ចៅកាំបិតបន្ទោះឃើញស្គាល់ជាស្តេចក្លែងភេទ ហើយក៏សំងំពួនបំបាំងនៅទីងសសរ ឯស្តេចក៏យាងមកដល់ បើកទតអស់ចំណីនៅដូចដែល ក៏ចៅកាំបិតបន្ទោះផងមួយស្រែកថា ពះកាប់អាចោរមកពីណាមកគិតលួចរបស់ស្តេចៗ នោះភ្ញាក់ភ័យរត់ទៅ ចៅកាំបិតបន្ទោះផងមួយ ក៏ដេញបណ្តោយទៅតាមស្តេចនោះៗ គេចខ្ទឹងសសរចុងព្រះពេង ចៅកាំបិតបន្ទោះកាប់ផុតៗ មិនត្រូវតែសសរចុងព្រះពផពេង ស្តេចគេចទៅសសរមួយទៀត ចៅកាំបិតបន្ទោះកាប់បង្ហុសទៀត ស្តេចគេចគ្រប់សសរ ចៅកាំបិតបន្ទោះក៏កាប់គ្រប់សសរគ្មានខ្វះសសរណាមួយឡើយ ឯកាំបិតបន្ទោះនោះ ទុកជាកាប់ត្រូវសសរក៏មិនដឹងជាដាច់ផង ។ លុះស្តេចស្រែកថា អញទេ ទើបចៅកាំបិតបន្ទោះផងមួយឈប់លែងកាប់ ហើយស្តេចត្រឡប់ចូលទៅក្នុងតំណាក់ទៅ ចៅកាំបិតបន្ទោះផងមួយក៏វិលមកចាំកន្ទេងផងដែលវិញ ។ លុះព្រឹកឡើងចៅកាំបិតបន្ទោះផងមួយក៏ត្រឡប់ទៅផ្ទះវិញ ខាងក្រោយចៅកាំបិតបន្ទោះទៅផ្ទះ ខ្យល់ក៏បក់ចុងព្រះពផពេងនោះរលំអស់ទៅ ទើបស្តេចឲ្យសួរថាបានខណាដេកចាំកំរិលយប់មិញនេះ ។

(មាឥត)

ឃុននិពន្ធមន្ត្រី ញ៉ុក-ថែម ស្រង់ប្រែនិងរៀបរៀង

អំពីគម្ពីរមិលិន្ទបញ្ហា (តមក)

## អង្គ ១ របស់ខ្ទួយ

មានកន្ទុយជាអាវុធ មានកន្ទុយងើងស្ទុតត្រចទៅ ។

ប្រៀបដូចអ្នកប្រតិបត្តិ មានប្រាជ្ញាញាណជាអាវុធ. លើកប្រាជ្ញាញាណឡើងកំចាត់កិលេស បន្ទោចនូវកិលេសដោយលំដាប់ បើកងកិលេសនៅមាន ក៏តាំងចិត្តតស៊ូដោយវិធីសំលៀងអាវុធ គឺញាណឲ្យមុតស្រួចទាល់តែអាចកំចាត់កងកិលេសបានជ្រះស្រឡះ ក៏យទាំងពួងក៏មិនអាចមកញាំញីគ្របសង្កត់បាន ។

## អង្គ ១ របស់ស្ការ:

កាលចូលទៅជិតពស់ រមែងយកថ្នាំលាបខ្លួនជាមុនហើយទើបចូលទៅចាប់ខាំពស់ ។

ប្រៀបដូចអ្នកប្រតិបត្តិ កាលចូលទៅជិតបុគ្គលដែលប្រឹនទៅដោយកំហឹងឃោរឃៅ ហើយជាអ្នកតែងមានការឈ្លោះវិវាទគ្នា គ្របសង្កត់សន្តានចិត្តផង ក៏យកថ្នាំគឺមេត្តាលាបឲ្យសព្វខ្លួនហើយរំលត់កំហឹងខឹងឃោរឃៅជាដើមនោះចេញ ធ្វើសន្តានរបស់ខ្លួននឹងជនទាំងឡាយឲ្យត្រជាក់ស្រួលដោយមេត្តាភាវនា ។

## អង្គ ១ របស់សត្វចាបៈ

នៅអាស្រ័យនឹងផ្ទះអ្នកដទៃ មិនដែលកាន់យកឬលួចយករបស់អ្វីមួយនៅក្នុងផ្ទះនោះឡើយ មានចិត្តទៀងទាត់ ប្រើនទៅដោយសញ្ញា (ការចាំ) ។

ប្រៀបដូចអ្នកប្រតិបត្តិ កាលទឹងចូលទៅកាន់ត្រកូលណាមួយ មិនគប្បីកាន់យកនិមិត្ត ក្នុងបុគ្គលទាំងរបស់អ្វីមួយក្នុងត្រកូលនោះៗ ទោះបីបុរស ស្ត្រី ទាសក ទាសិកា គ្រឿងឧបភោគបរិភោគ ទាំងគ្រឿងប្រើប្រាស់ផ្សេងៗ គប្បីជាអ្នកមធ្យស្ថប្រយ័ត្នខ្លួន តាំងសមណសញ្ញាឲ្យប្រាកដប្រាសក្នុងចិត្តជានិច្ច ។

## អង្គ ១ របស់ក្អែកៈ

កាលស្រែកយំឡើង តែងប្រាប់ហេតុល្អឬអាក្រក់ ឲ្យគួរឲ្យខ្លាច ដល់មនុស្សដទៃ ។

ប្រៀបដូចអ្នកប្រតិបត្តិ កាលទឹងសំដែងធម៌ដល់ជនដទៃ គប្បីសំដែងហេតុផលទាំងល្អទាំងអាក្រក់ ឲ្យមានទុក្ខបានជាគ្រឿងសាងឲ្យអ្នកស្តាប់មាននេសេចក្តីសង្វេគស្លុតចិត្ត ហើយឲ្យមានចិត្តសប្បាយរីករាយក្នុងការប្រតិបត្តិតាមធម៌ ។

## អង្គ ១ របស់ឈ្លើង:

តាមមនុស្សប្រុសគូណា ក៏ចាប់កោះមនុស្សប្រុសគូនោះយ៉ាងខ្ជាប់ខ្ជួន ហើយស្រូបយកលោហិត ។

របៀបដូចអ្នកប្រតិបត្តិ គប្បីចាប់យកអារម្មណ៍ណាមួយមកទុកឲ្យជាប់មាំនៅក្នុងចិត្ត ពិចារណាឲ្យឃើញច្បាស់ដោយពណ៌សណ្ឋានដោយនិមិត្ត ហើយគប្បីផញ្ញក់យករសគឺវិមុត្តិឲ្យបាន ។

## អង្គ ១ របស់ពស់ហ្លាន់:

ជាសត្វធំ មានរាងកាយធំ ទុកជាមានពោះស្គួតក្រៀមជាច្រើនថ្ងៃ ព្រោះស្វែងរកអាហារមិនបានពេញពោះ កាលជាក់ធំពេញបន្ទុកហើយ តែងចិញ្ចឹមជីវិតឲ្យល្មមតែរាងកាយទ្រទ្រង់នៅបានប៉ុណ្ណោះ ។

របៀបដូចអ្នកប្រតិបត្តិ បំពេញព្យាយាមខ្វល់ខ្វាយដើរបិណ្ឌបាតអាស្រ័យដុំបាយរបស់អ្នកស្រុក មានបំណងតែដុំបាយដែលគេឲ្យ វៀរចាកស្ងួតណ្តាំខ្លួនឯង ស្វែងរកអាហារឲ្យបានពេញពោះបានដោយកម្រ សូម្បីបានអាហារមករច្រើនក៏ឆាន់តែល្មមប្រមាណ ដល់គ្រាបានអាហារតិចត្រឹម ៤-៥-មាត់ ក៏យកមកប្រែបល់ប្រញាប់ទឹកឆាន់ (ល្មមតែទ្រទ្រង់ជីវិតឲ្យគង់វង់នៅប៉ុណ្ណោះ) ។

## អង្គ ១ របស់សត្វពីងពាងធ្វើសំបុកក្បែរផ្លូវ៖

ហូតទាញសរសៃក្រាលសំណាញ់នៅក្បែរផ្លូវ បើមានរុយឬមមង់ហើរទៅប៉ះជាប់នៅនឹងសំណាញ់នោះ ពីងពាងក៏ចាប់សត្វដែលជាប់នៅនឹងសំណាញ់នោះស៊ីជាអាហារ ៗ

ប្រៀបដូចអ្នកប្រតិបត្តិ ចំរើនសតិបដ្ឋានដូចសរសៃពីងពាងហើយរក្សាទ្វារទាំង ៦ ទុក បើមានកិលេសដូចជារុយកើតឡើងក៏គប្បីកំចាត់បង់ដោយសតិបដ្ឋាននោះភ្លាមទៅ ៗ

## អង្គ ១ របស់ទារកបៅដោះ៖

លើកឡើងចង់រកតែបៅដោះ ស្រែកយំអង្វរសុំដោះម្ដាយបៅតាមសេចក្ដីស្រេកឃ្លានរបស់ខ្លួន ៗ

ប្រៀបដូចបុគ្គលអ្នករក្សាប្រយោជន៍របស់ខ្លួនទុក ជាអ្នកគាប់ចិត្តតែក្នុងប្រយោជន៍ខ្លួន ។ ស្វាហាប់សាកសួរការសង្ស័យ គាប់ចិត្តប្រកបព្យាយាមត្រង់ទៅក្នុងសេនាសនៈស្ងាត់ នៅរួមនឹងអ្នកប្រាជ្ញទាំងឡាយ ខ្ចប់កល្យាណមិត្តទុកជាគ្រូរៀនសូត្ររួមទុកក្នុងករណីយកិច្ចទៅ ៗ

## អង្គ ១ របស់ក្អម៖

ក្អមដែលមានទឹកពេញប្រៀប ទុកជាមានគេគោះ ក៏មិនមានឮសូរសព្ទពាន់ឡើយ ៗ

ប្រៀបដូចអ្នកប្រតិបត្តិបានដល់ថ្នាក់កល្យាណជនពេញទី ថ្មួយ បានសម្រេចអរិយមគ្គអរិយផលហើយ ក៏មិនបានអួតអាងប្រកាសប្រាប់គេឯង ទាំងមិនជាប់ចិត្តនឹងលាភសក្ការៈ ដែលកើតឡើងតាមធម្មតា ព្រោះតែគុណវិសេសនោះ ជាអ្នកកំចាត់មានះបានហើយ កំចាត់អំនួតបានហើយ ជាអ្នកត្រង់ទៅត្រង់មក មានក់ហមិនសាហាវ មានកាយមិនក្រអេតក្រអឺត ជាអ្នកសុភាពរៀបរយជានិច្ច ។

ឮការមានអង្គពីរ

## អង្គ ២ របស់ខ្លាឈ្មោល:

១- លាក់ខ្លួនពួននៅកន្លែងស្ងាត់ ចាំលោតចាប់ពួកសត្វម្រឹគស៊ីជាអាហារ ។

២- សត្វណានិមួយ ដែលវាចាប់បានហើយ បើដួលទៅខាងឆ្វេង ក៏មិនព្រមស៊ី ។

ប្រៀបដូចអ្នកប្រតិបត្តិប្រកបដោយអង្គសម្បត្តិ ២ ប្រការគឺ:

១- សេពសេនាសនៈដ៏ស្ងាត់ ចំរើនភាវនាត្រាតែស្ងាត់ជំនាញក្នុងអភិញ្ញា ៦ ។

២- មិនបរិភោគភោជនាហារដែលសម្រេចមកដោយមិច្ឆាជីវៈ ដែលព្រះពុទ្ធទ្រង់ត្មះតិះដៀលទឹងដែលកើតមកអំពីអនេសនកម្ម យ៉ាងដូចខ្លាដំបងមិនព្រមស៊ីសត្វដែលដួលទៅខាងឆ្វេង ដូច្នោះ ។ (មានត)

## ពិធីបុណ្យក្នុងក្រសួងពុទ្ធសាសនបណ្ឌិត្យ

ពិធីចែកសញ្ញាបត្រ-រង្វាន់ដល់ព្រះសង្ឃជាសិស្សសាលាបាលីជាន់ខ្ពស់

## នៅថ្ងៃ ៩ ខែមេ ឆ្នាំ ១៩៤៤

ម៉ោង ៩ ព្រឹក ក្រសួងពុទ្ធសាសនបណ្ឌិត្យ បានរៀបចំធ្វើពិធីចែកសញ្ញាបត្រនិងរង្វាន់ ដល់ព្រះសង្ឃជាសិស្សសាលាបាលីជាន់ខ្ពស់ ២៨ រូបគឺៈ សិស្សដែលប្រឡងជាប់ចំនួន ២២ រូប ត្រូវបានសញ្ញាបត្រ សិស្សស្លាប់ ៦ រូប ត្រូវបានសិក្ខាបត្រ, ក្នុងពិធីបុណ្យនេះ សម្តេចព្រះមហាសុមេធាធិបតី (ហ៊ិន) សង្ឃនាយកគណៈមហានិកាយ ព្រះសុធម្មាធិបតី (ស៊ី) សង្ឃនាយកគណៈធម្មយុត្តិ លោកអ្នកឧកញ៉ាអគ្គមហាសេនា (អ៊ិង អ៊ី) សេនាបតីក្រសួងធម្មការ និងលោកដេ. ឡោះគ (បារូល) បាននិមន្តនិងអញ្ជើញទៅជាអធិបតីក្នុងឱកាសចែកសញ្ញាបត្រនិងរង្វាន់ ដល់ព្រះសង្ឃជាសិស្សទាំងនោះ ។

*

* *

## ពិធីបំពាក់គ្រឿងឥស្សរិយយស

និង

## ប្រគល់ព្រះរាជក្រឹត្យដែលតាំងងារ

វេលារសៀលម៉ោង ១៧ (ម៉ោង៥) ថ្ងៃខែដដែលនេះ បានប្រជុំមួយលើកទៀត លោកអគ្គលេខាធិការ នៃពុទ្ធសាសនបណ្ឌិត្យ

(ឌុយប៊ុនតំ) នឹងព្រះនាយកមន្ត្រី (យៀន-ចិប) ជាអធិបតី បានបំពាក់គ្រឿងឥស្សរិយយសឲ្យមន្ត្រីដែលទទួលក្រឹត្យតាំង ៥ រូបគឺ:

១— លោកគ្រូព្រះអាចារ្យ សៅ-មៀច គ្រឿងឥស្សរិយយស មុនីសារគុណ ៗ

២— ឧកញ៉ាលេខានុរក្ស ឡាយ-គឹក " " សុវត្តផាក ៗ

៣— ហ្លួងរតនានុរក្ស គង់-ដាំ " " អស្សឫទ្ធិក្រុងកម្ពុជា ៗ

៤— ឃុនបំណាងអក្សរ លិម-កង " " មុនីសារគុណ ៗ

៥— លោក ទាស-យ៉ី " " មុនីសារគុណ ៗ

រួចកិច្ចនេះហើយ បានប្រគេនសមណសក្តិដែលតាំងថ្មី ដល់ព្រះសង្ឃ ១១ អង្គ ដូចកយនាមនឹងសមណសក្តតទៅនេះ:

១— ព្រះបាឡាត់ វណ្ណ-សាឌុម ក្រុមជំនុំព្រះត្រៃបិដក វត្តនន្ទមុនីរាម ត្រូវឡើងជាទីព្រះគ្រូ សុមេធគ្រូ ៗ

២— លោកគ្រូ ប៉ែន-សុខ គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ វត្តឧណ្ណាលោម ជាទីព្រះគ្រូ ញាណសត្ថា ៗ

៣- លោកគ្រូ សួរ-ហាយ គ្រូបង្រៀនព្រះត្រៃបិដក វគ្គឧត្តមលោម ជាទីព្រះគ្រូ សុវណ្ណញាណ ។

៤- លោកគ្រូ គម-គួ " " ជាទីព្រះគ្រូ សិរីសោភ័ណ ។

៥- លោកគ្រូ ពាង-សុខ " " ជាទីព្រះគ្រូ សច្ចវិទូ ។

៦- លោកគ្រូ អៀង-ថ្វាង " " ជាទីព្រះគ្រូ អរិយវិទូ ។

៧- លោកគ្រូ ម៉េញ-ណាគ្រី " " ជាទីព្រះគ្រូ ធម្មវិទូ ។

៨- លោកគ្រូ កោ-ស៊ឹម អ្នកត្រួតត្រាសិស្សសាលាបាលីជាន់ខ្ពស់ វគ្គលេខ៍ ជាទីព្រះគ្រូ បញ្ញាលិខិត ។

៩- លោកគ្រូ ឈឹម-ស៊ុម គ្រូបង្រៀនសាលាបាលីជាន់ខ្ពស់ វគ្គលេខ៍ ជាទីព្រះគ្រូ អរិយសត្ថា ។

១០- លោកគ្រូ សោម-ឡុប គ្រូបង្រៀនព្រះត្រៃបិដក វគ្គលេខ៍ ជាទីព្រះគ្រូ មុនីសោភ័ណ ។

១១- លោកគ្រូ គុយ-ស្រូក គ្រូបង្រៀនព្រះត្រៃបិដក វគ្គសោភន ជាទីព្រះគ្រូ សាសនវង្ស ។

ស្រេចកិច្ចនេះហើយ ទើបលោកអគ្គលេខាធិការនៃពុទ្ធសាសន-
បណ្ឌិត្យ ប្រគល់ព្រះរាជក្រឹត្យដែលឲ្យឡើងយសសក្តិនិងងារកិត្តិយស
ដល់អ្នករាជការគ្រហស្ថ ២៦ នាក់ ដូចមានរាយឈ្មោះនិងងារតទៅនេះ:

១- ឧកញ៉ា សោភ័ណមន្ត្រី ជួន-នុត ត្រូវបានឡើងសក្តិ ដល់ ៨ ហ៊ូពាន់ ។

២- ឧកញ៉ា ទេពពិទូ ឈឹម-ក្រសេម ជាឡេវត្រី ១ បាន ឡើងសក្តិដល់ ៨ ហ៊ូពាន់ ។

ត្រូវបានឡើងពីទីឃុនទៅទីហ្លួង សក្តិ ៥ ហ៊ូពាន់គឺ:

៣- ឃុនទិព្វមន្ត្រី ញ៉ុក-ថែម ឡេវត្រី ២ ។

៤- ឃុនសារពិនិត្យ ព្រំ-គ្រូប សៀន ។

៥- ឃុនវិចិត្រពោហារ អ៊ុក-សេន សៀន ។

ត្រូវឡើងពីទីហ្មឺនទៅទីឃុនសក្តិ ៤ ហ៊ូពាន់គឺ:

៦- ហ្មឺន បណ្ណារក្ស ប៊ូ-ប៊ូ. សៀន

៧- ហ្មឺន មហាវេទ ទិន-ហ្លួត. "

៨- ហ្មឺន វរមេធ អ៊ុក-ម៉ុត. "

៩- ហ្មឺន សត្ថមន្ត្រី ឡុង-ជា. "

១០- ហ្មឺន ឧត្តមប្រជា ហាប-តិន. " ។

អ្នកពង់ការ ទទួលងារកេត្តិយសបត្តិ

| | | | | |
|---|---|---|---|---|
| ១១- | ហួន វិសុទ្ធមេធា | អ៊ុំ-សេរ៉ | គ្រូបង្រៀនបាលី | ទ |
| ១២- | ហួន បណ្ណានុបាល | លាប-លាន | ស្មៀន | ទ |
| ១៣- | យុន សិរីមេធ | ស្រី-អ៊ូ | " | ទ |
| ១៤- | យុន អត្ថកោវិទ | ជា-យូ | " | ទ |
| ១៥- | យុន បញ្ញាសោភណ | តាំ-ឌុំ | " | ទ |
| ១៦- | យុន ពាសេសសុធ | ឯន-ជន់ | " | ទ |
| ១៧- | យុន សុវត្ថវេទ | យ៉ូ-ស៊ុន | " | ទ |
| ១៨- | យុន វិទ្យានុសង្ឃ | មាង-នាង | " | ទ |
| ១៩- | យុន សុន្ទរមេត្រី | ឯម-មីសែល | លេខានុការ | ទ |
| ២០- | យុន ពិនិត្យសម្បត្តិ | ហោន-សន | " | ទ |
| ២១- | យុន បណ្ណានុសិទ្ធិ | សុខ-មៀន | ស្មៀន | ទ |
| ២២- | យុន ប្រសិទ្ធិអក្សរ | ហេង-សេង | " | ទ |
| ២៣- | យុន ពិចិត្រអក្សរ | កែ-វ៉ែម | " | ទ |
| ២៤- | យុន អក្ខានុគិជ្ជ | យក់-ស៊ុន | " | ទ |
| ២៥- | យុន វិបុលប្រជា | ប្រាក់-ឈួក | លេខានុការ | ទ |
| ២៦- | យុន ចំណានអក្សរ | លឹម-គង់ | ស្មៀន | ទ |

## កាព្យពាក្យ ៧

### ថ្លែងតាមមុខងារនៃមន្ត្រីទាំង ២៦ ឈ្មោះខាងដើមនេះ

ថ្ងៃប្រាំបួនមេ៉ឆ្នាំសែបួន ជួបជួនចំរើនយសសក្តា មន្ត្រីក្រសួងពុទ្ធសាសនា ឃុន-ហ្លួង
ឧកញ៉ាតាមលំដាប់ ។

១) លោកឧកញ៉ាសោភ័ណមន្ត្រី ធ្វើការមានថ្វីដៃចំណាប់
ជាអ្នកត្រួតត្រាតឹងកាន់កាប់ ប្រាក់កាសសម្រាប់ចាត់ចែងការ ។ (ជួន-នុន)

២) បន្ទាប់មកឧកញ៉ាទេពពិទូ ជាគ្រូខាងលទ្ធិសាសនា
អ្នកប្រាជ្ញប្រវត្តិពង្សាវតារ ទំនៀមដូនតាពីបុរាណ ។ (ឈឹម-ក្រសេម)

៣) ហ្លួងនិពន្ធមន្ត្រីជាបណ្ឌិត អ្នកគិតតែងរឿងយ៉ាងចំណាន
បោះពុម្ពរាល់ខែឥតអាក់ខាន ចែកញាតិសន្តានដែលត្រូវការ ។ (ញ៉ុក-ថែម)

៤) ហ្លួងសារពិនិត្យជាអ្នកលក់ តាយកសៀវភៅគ្រប់ភាសា
បញ្ជីប្រាក់ចូលសឹងកត់ត្រា រក្សាមិនឲ្យខាតអន្តរាយ ។ (ក្រិ-ក្រូច)

៥) ហ្លួងវិចិត្រភិហារប្រាជ្ញាជ្រៅ ចេញទៅគ្រប់ខែត្រទោះជិតឆ្ងាយ
យកក្បួនសាសនាទៅចែកចាយ ឲ្យជនទាំងឡាយមើលគ្រប់ប្រាណ ។ (អ៊ុក-សេន)

៦) ហ្លួងវិសុទ្ធមេធាជាអាចារ្យ បង្រៀនសាស្ត្រាច្បាប់បុរាណ
ប្រែពីបាលីតាមលំអាន ឲ្យសិស្សផងបានចេះគ្រប់គ្នា ។ (អ៊ុច-រស់)

៧) ហ្លួងបណ្ណាធុបាលអ្នករក្សា កត់ត្រាសៀវភៅផងនានា
ដែលមានគេខ្ចីទៅទស្សនា ដល់ពេលត្រូវទារមកទុកនៅ ។ (លាប-លាន)

៨) ឃុនបណ្ណាធុរក្សក៏ដូចគ្នា ថែទាំការពារគ្រប់សៀវភៅ
កត់ត្រាឈ្មោះណាដែលខ្ចីទៅ កុំឲ្យសៀវភៅខូចចឹងអ្វី ។ (ប៊ូ-ប៊ូ)

៩) ឃុនមហាវេទីវិសេសណាស់ ចេះច្បាស់ខាងភាសាបាលី
ផ្ទៀងត្រៃបិដកដែលប្រែថ្មី នៅបុរីទក្ខិណាភិរម្យ ។ (ទិន-ហ្លួត)

១០) យុវនារីមេធាវីអ្នកប្រាជ្ញ ថ្វីមាត់អន់អាចគួរទិយេះ
ក្នុងកិច្ចទាក់ណាក៏រៀប . ភាគខាងកែសំណើជាស់ ។ (គុក - ម៉ុន)

១១) យុវសេដ្ឋមន្ត្រីអ្នកពិនិត្យ ឥតខ្ចីលើកវិតច្រើនជើរជាស់
ទុកដាក់ដោយបែកតាមស្តើងក្រាស់ ណាខ្វះបានដែនទៀតឲ្យបាន ។ (ឡុង-ដា)

១២) យុវឧត្តមប្រឹក្សាមេធាវី រក្សាបញ្ជីក្បួនបុរាណ
ដែលគេផ្ញើមកទាំងប៉ុន្មាន នឹងទំនិតអានតែងរៀងផង ។ (វាច-ពិន)

១៣) យុវសិរីមេធីក្រុមជំនុំ ជួបជុំខាងក្រុមប្រែចំឡង
កាត់កាច់បញ្ជីការគួកកោះ ពេលម៉ោងម្ដងៗ ឲ្យជាក់ស្ដែង ។ (ស្រី-អ៊ុ)

១៤) យុវអគ្គកោវិទពិតជាប្រាជ្ញ វេយ្យាករណ៍អាចឥតកោតក្រែង
ដោះស្មៀមវាលីយ៉ាងវែងវែង ប្រែអ្វីជាក់ស្តែងគួរចង់ស្តាប់ ។ (ផា-យូ)

១៥) យុវបញ្ញាសោភ័ណត់និតរៀត ភតិការឲ្យទៅកត់ក្បួនច្បាប់
បុរាណវត្ថុតាមលំដាប់ ធ្វើការចំណាប់ខាងជើរផ្សុរ ។ (តាំ-នុំ)

១៦) យុវតិសេសសុធិដោះល្បៀនល្បែប យល់កល់ស្កាល់កិច្ចការខុសត្រូវ
ជាអ្នកត្រូតត្រាកែនត្រូវ ឲ្យត្រូវតាមច្បាប់លោកបង្គាប់ ។ (ឯម - ប៉ីង)

១៧) យុវសុវត្ថិវេទីប្រាជ្ញាច្រើន ចំរើនខាងមើលច្បាប់ទម្លាប់
សរសេរឲ្យតម្កល់ដោយខ្លួនខ្ជាប់ រាប់ជាអ្នកដោះចំឡង ។ (យូ - អ៊ុន)

១៨) យុវវិទ្យានុសិដ្ឋចិត្តបរិសុទ្ធ ភាសាបំផុតខាងល្បិចល្បង
ស្គាល់ក្បាច់បុរាណពានហ្មត់ហ្មង ចេញទៅចំឡងផ្តិតមកវិញ ។ (ម៉ាង - ទាង)

១៩) យុវសុន្ទរមន្ត្រីស្មារតីវែង ឬកពានំងធំងរូបប្រិមប្រិយ
ទុកដាក់សំណុំរៀងអ៊ីវ ឥតបីឲ្យបាត់បង់ទៅណា ។ (ឯម - មីសែល)

២០) យុវពិនិត្យសម្បត្តិអ្នកបាត់ដែង ខ្វះខ្វែងបើកប្រាក់ពីរាជការ
យកទុកចាយវ៉ាយតាមប្រាជ្ញា ចត់ត្រាបញ្ជីឥតភ្ញាត់ភ្លាំង ។ (ឈ្មោក - សន)

២១) យុវចណ្ណានុសិទ្ធិចិត្តស្មោះត្រង់ ផ្ទិតផ្ទង់រក្សាបញ្ជីឃ្លាំង
ទិនឲ្យបាត់បង់ដោយភាន់ភាំង សៀវភៅទាំងអស់សីគក់ត្រា ។(សួន-ខៀន)

២២) ឃុនឫស្សីទុំអក្សរល្អប្រពៃ កំពិតការវែកញែករចនា
គួរគួរអក្សរល្អថ្លៃថ្លា ដោះការជជែកក្របសៀវភៅផង ។ (ហេង-សេង)
២៣) ឃុនពិចិត្រអក្សរស្រស់ចំណាំ សរសេរបានសព្វគតសោហ្មង
ដុំ១ការដាក់ផ្អកចាំជំរួង ច្បាប់ផងដែលក្រសួងបោះពុម្ពផ្សាយ ។ (វ៉ែក-វ៉េយ៉ុង)
២៤) ឃុនអក្ខរានុកិច្ចកបលក្ខណា ដោះបារសាស្ត្រាផងស្រស់ស្រាយ
ចំឡងរឿងរ៉ាវគងតាំងឡាយ ដើម្បីវែកបាយមើលត្រូវគ្នា ។ (យក់-អ៊ុន)
២៥) ឃុនពិបុលប្រីជាប្រាជ្ញាច្រើន ធ្វើការចំរើនគ្រប់ប្រការ
បញ្ជីបៀវត្សអ្នករាជការ ក្រសួងសាសនាបណ្ឌិត្យអើយ ។ (ប្រាក់-ឈួក)
២៦) ឃុនចំណានអក្សរបុណ្យអស្ចារ្យ ទទួលមុខការយ៉ាងចំឡែក
អ្នកលក់សៀវភៅដែលថ្លៃក នៅបែកខាងក្រុមរទេះភ្លើង ។ (ល័ម-កង)

## ចៅអធិការទំាងមន្ត្រីសង្ឃ

ដែលទើបតាំងថ្មីរវាងខែហ្វេវ្រីយេរ-ម៉ារ្ស ១៩៥៥

១ - សញ្ញាប័ត្រលេខ ៥ ចុះថ្ងៃ ៦-២-៥៥ តាំងគ្រូសូត្រ ក្រៀល-អ៊ីង កើតឆ្នាំរោង អាយុ ៤០ វស្សា ១២ នាមធាយោ ធម្មត្ថេរ ជាចៅអធិការវត្តថ្កូស ឃុំកំពង់ឆ្នាំង ស្រុករលាប្អៀរ ។

២ - សញ្ញាប័ត្រលេខ ៦ ចុះថ្ងៃ ១៥-២-៥៥ តាំងគ្រូសូត្រ សួន-ទូ កើតឆ្នាំជូត អាយុ ៥៥ វស្សា ៥ នាមធាតោ សុវណ្ណបញ្ញា ជាចៅអធិការវត្ត ទ្រព្យគរ ឃុំត្រពាំងសាប ស្រុកបាទី ។

៣ - សញ្ញាប័ត្រលេខ ៧ ចុះថ្ងៃ ១៥-២-៤៤ តាំងគ្រូសូត្រ ឡាំង-ថាញ់ កើតឆ្នាំថោះ អាយុ ២៥ វស្សា ៩ នាមឆាយា ញាណធម្ម-វិទូរយ ជាចៅអធិការវត្តតេនាកម ឃុំលេខ ៥ ក្រុងភ្នំពេញ ។

៤ - សញ្ញាប័ត្រលេខ ៨ ចុះថ្ងៃ ១-៣-៤៤ តាំងគ្រូសូត្រ តាច-ទូ កើតឆ្នាំថោះ អាយុ ៥២ វស្សា ៣០ នាមឆាយា ញាណគុត្ត ជាចៅអធិការវត្ត មេព្រីង ឃុំមេព្រីង ស្រុកជើងព្រៃ ។

៥ - សញ្ញាប័ត្រលេខ ៩ ចុះថ្ងៃ ៦-៣-៤៤ តាំងគ្រូសូត្រ ស៊ូ-ជោង កើតឆ្នាំរកា អាយុ ៥៩ វស្សា ៣៨ នាមឆាយា សិរីបុត្ត ជាវិន័យធរគណវត្តពោធិ៍អណ្តែត ឃុំកំពង់ហាវ ស្រុកកំពង់លែង (កំពង់ឆ្នាំង) ។

៦ - សញ្ញាប័ត្រលេខ ១០ ចុះថ្ងៃ ៦-៣-៤៤ តាំងគ្រូសូត្រ អៀម-លី កើតឆ្នាំកុរ អាយុ ៤៥ វស្សា ២៥ នាមឆាយា ឥន្ទបញ្ញា ជាសមុហ៍គណវត្តកំពង់បាចិន ឃុំពោធិ៍ (កំពង់លែង) ។

៧ - សញ្ញាប័ត្រលេខ ១១ ចុះថ្ងៃ ៦-៣-៤៤ តាំងគ្រូសូត្រ ជិត-ហ៊ាន កើតឆ្នាំមមី អាយុ ៣៨ វស្សា ១៧ នាមឆាយា ឥន្ទគុត្ត ជាលេខាធិការគណវត្តក្តីក្រោម ឃុំត្រងិល ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ។